# សេចក្តីព្រាងច្បាប់
# ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១._គោលបំណង**

ច្បាប់នេះមានគោលបំណង៖

- កំណត់បទប្បញ្ញត្តិ គោលការណ៍ បទដ្ឋាន នីតិវិធី និងវិធានស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថានសម្រាប់រាល់គម្រោងវិនិយោគទាំងអស់ ដែលបង្កហេតុប៉ះពាល់ និងគ្រោះថ្នាក់ដល់បរិស្ថាន សង្គម សេដ្ឋកិច្ច វប្បធម៌ នីត្យានុកូលភាព និងលទ្ធិប្រជាធិបតេយ្យរបស់រដ្ឋ។
- បញ្ញត្តិអំពីដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជំរុញឲ្យមានការចូលរួមជាសាធារណៈនិងអនុវត្តឲ្យតឹងរ៉ឹងនៃការអនុវត្តច្បាប់នេះ ដើម្បីធានាការអភិវឌ្ឍន៍បៃតងដែលជាការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

**មាត្រា២._វិសាលភាពអនុវត្ត**

- ច្បាប់នេះមិនផ្ទុយនឹងច្បាប់ជាធរមានរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចផ្តល់ការអនុញ្ញាតលើការអភិវឌ្ឍតាមវិស័យ ដូចជា ការវិនិយោគក្នុងវិស័យ ពាណិជ្ជកម្ម ឧស្សាហកម្ម និងសកម្មភាពអាជីវកម្មឡើយ។ រាល់គម្រោងអភិវឌ្ឍន៍ និងសកម្មភាពអាជីវកម្មដែលទទួលបានការអនុញ្ញាតពីក្រសួងស្ថាប័នដទៃទៀតរួច នៅតែគោរពតាមច្បាប់នេះ។
- ច្បាប់នេះមានវិសាលភាពអនុវត្តទាំងស្រុង និងយ៉ាងពេញលេញ ចំពោះរាល់បាតុភូត និងសកម្មភាពគម្រោងទាំងអស់របស់រូបវន្តបុគ្គលម្ចាស់កម្មសិទ្ធិគ្រប់ប្រភេទ នីតិបុគ្គលឯកជន នីតិបុគ្គលសាធារណៈ អង្គភាពនិងស្ថាប័នរដ្ឋ រដ្ឋនិងរដ្ឋ ដែលស្ថិតក្រោមដែនសមត្ថកិច្ចនៃច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ហើយដែលបានប្រតិបត្តិការរួច កំពុងប្រតិបត្តិការ ឬនឹងចាប់ផ្តើមប្រតិបត្តិការដែលអាចនាំឲ្យកើតមានហេតុប៉ះពាល់ដល់បរិស្ថាន និងសង្គម។
- ចាប់ពីពេលច្បាប់នេះចូលជាធរមាន រាល់ស្ថាប័នរដ្ឋ ក្រសួង មន្ទីរ និងអង្គភាពសាធារណៈរបស់រដ្ឋទាំងអស់ ត្រូវយកច្បាប់នេះជាគោលការណ៍អនុវត្តជាសំខាន់មុននឹងសម្រេចផ្តល់ការអនុញ្ញាត ចេញអាជ្ញាប័ណ្ណ និងសេចក្តីសម្រេចនានា។
- រាល់សកម្មភាព និងគម្រោងអភិវឌ្ឍន៍ជារូបវន្តបុគ្គល នីតិបុគ្គលឯកជននិងនីតិបុគ្គលសាធារណៈត្រូវគោរពបទប្បញ្ញត្តិនៃច្បាប់នេះ ឲ្យបានតឹងរ៉ឹង។រាល់បែបបទ នីតិវិធីអនុវត្ត និង

បទដ្ឋានបច្ចេកទេស ដែលមិនមានចែងក្នុងច្បាប់នេះ ត្រូវកំណត់នៅក្នុងអនុក្រឹត្យ ប្រកាស សារាចរ និងសេចក្តីណែនាំនានាតាមសំណើរបស់រាជរដ្ឋាភិបាល ឬក្រសួងបរិស្ថាន។

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាព និងគម្រោងអភិវឌ្ឍន៍នានា ដែលទទួលបានលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ សេចក្តីសម្រេចពីក្រសួង និងស្ថាប័នអនុម័តគម្រោង ហើយមិនបានសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

## មាត្រា៣._គម្រោងលើកលែង

ច្បាប់នេះមិនអនុវត្តចំពោះគម្រោងរបស់រដ្ឋដែលបានសម្រេចដោយរាជរដ្ឋាភិបាល ឬបានអនុម័តពីរដ្ឋសភា ហើយដែលត្រូវបានចាត់ទុកជាគម្រោងបន្ទាន់ទាក់ទងនឹងវិស័យសន្តិសុខជាតិ ការពារជាតិ និងការគ្រប់គ្រងគ្រោះមហន្តរាយ។

## មាត្រា ៤._និយមន័យសទ្ទានុក្រមនិងអក្សរកាត់

និយមន័យ សទ្ទានុក្រម អក្សរកាត់ ជាភាសាខ្មែរនៃច្បាប់នេះមានចែងក្នុងឧបសម្ព័ន្ធ។

# ជំពូកទី ២
# គោលការណ៍ និងសិទ្ធិអំណាច

## មាត្រា ៥._បទប្បញ្ញត្តិស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

រាល់គម្រោងអភិវឌ្ឍន៍ទាំងអស់ត្រូវធ្វើការវាយតំលៃហេតុប៉ះពាល់ទៅលើបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ឲ្យបានត្រឹមត្រូវជាមុនសិន មុននឹងបញ្ជូនទៅរាជរដ្ឋាភិបាលឯកភាព និងអនុម័ត។ ប្រភេទគម្រោងអភិវឌ្ឍន៍ដែលតម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ។

រាល់គម្រោងអភិវឌ្ឍន៍ទាំងអស់ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យ មិនត្រូវចាប់ផ្តើមការងារសាងសង់ដោយគ្មានលិខិតឯកភាពលើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានចេញដោយក្រសួងបរិស្ថាន។

ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន សង្គមស៊ីវិល និងអ្នកដែលទទួលរងហេតុប៉ះពាល់មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានក្នុងអំឡុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

## មាត្រា៦._គោលការណ៍ដែលត្រូវអនុវត្ត

ដើម្បីសម្រេចបាននូវវត្ថុបំណងនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព គោលការណ៍ដូចខាងក្រោមត្រូវយកមកអនុវត្ត ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ត្រូវផ្តល់សិទ្ធិទទួលបាននូវព័ត៌មាន ដែលបានផ្តល់ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានចំពោះក្រសួង/ស្ថាប័នពាក់ព័ន្ធមន្ទីរនានានៃរាជរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិលអ្នកដែលទទួលរងហេតុប៉ះពាល់ពីគម្រោង និងសាធារណជនដើម្បីរួមចំណែកការពារសិទ្ធិ

របស់បុគ្គលគ្រប់រូបក្នុងព្រះរាជាណាចក្រកម្ពុជា នាបច្ចុប្បន្ន និងអនាគត ក្នុងការចូលរួមក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

បុគ្គលគ្រប់រូបក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមានលទ្ធភាពទទួលបាននូវយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន ដើម្បីបង្កើនគុណភាពនៃការធ្វើសេចក្តីសម្រេចក្នុងបញ្ហាបរិស្ថាន និងដើម្បីលើកកម្ពស់តម្លាភាពនៃការធ្វើសេចក្តីសម្រេចក្នុងបញ្ហាបរិស្ថាន ។

កិច្ចដំណើរការវាយតំលៃបរិស្ថានត្រូវលើកទឹកចិត្ត និងផ្តល់លទ្ធភាពដល់សាធារណជន និងសង្គមស៊ីវិលចូលរួមក្នុងកិច្ចការពារបរិស្ថាន នៅក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

កិច្ចដំណើរការវាយតំលៃបរិស្ថានត្រូវទទួលស្គាល់ការចូលរួមរបស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន សង្គមស៊ីវិល សាធារណជនអ្នកដែលទទួលរងនូវហេតុប៉ះពាល់ពីគម្រោងជាទិដ្ឋភាពដ៏សំខាន់នៃការវាយតំលៃបរិស្ថាន។

កិច្ចដំណើរការវាយតំលៃបរិស្ថាន ត្រូវប្រកាន់យក និងអនុវត្តគោលការណ៍បង្ការទប់ទល់ពោលគឺពេលមានការគម្រាមកំហែងនៃការខូចខាតបរិស្ថានធ្ងន់ធ្ងរ ឬមិនអាចជួសជុលបាន កង្វះភាពច្បាស់លាស់ខាងវិទ្យាសាស្ត្រមិនត្រូវបានយកមកធ្វើជាមូលហេតុដើម្បីផ្អាកការអនុវត្តវិធានការការពារការខូចគុណភាពបរិស្ថានឡើយ។

កិច្ចដំណើរការវាយតំលៃបរិស្ថានត្រូវប្រកាន់យក និងអនុវត្តគោលការណ៍ "អ្នកបង្កការខូចខាតបរិស្ថានត្រូវទូទាត់សំណង" ដោយបុគ្គលដែលបង្កឲ្យមានការបំពុលបរិស្ថាន និងសំណល់ ឬបង្កការខូចខាតដល់បរិស្ថាន ត្រូវរ៉ាប់រងបង់ថ្លៃចំណាយខូចខាត ការទប់ស្កាត់ ការជៀសវាង ឬការកាត់បន្ថយការខូចខាត។

កិច្ចដំណើរការវាយតំលៃបរិស្ថាន ត្រូវពិចារណាពីបម្រែបម្រួលអាកាសធាតុ និងហេតុប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុដែលអាចមានមកលើគម្រោងនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា៧._ករណីយកិច្ចទូទៅនៃកិច្ចការពារបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវអនុវត្តសកម្មភាព ឬគម្រោងណាមួយដែលបង្ក ឬអាចបង្កការខូចខាតដល់បរិស្ថានឡើយ លើកលែងតែបុគ្គលនោះអនុវត្តនូវវិធានការសមស្រប និងអាចអនុវត្តបាន ដើម្បីបង្ការ និងកាត់បន្ថយការខូចខាតនោះ

ករណីយកិច្ចនេះជាករណីយកិច្ចបន្ថែមលើកាតព្វកិច្ចទាំងឡាយ ដែលបានកំណត់ដោយក្រសួងបរិស្ថាន ក្នុងវិញ្ញាបនប្រតងកភាពការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

# ជំពូកទី ៣
# ស្ថាប័នទទួលខុសត្រូវ

## មាត្រា៨._ស្ថាប័នមានសមត្ថកិច្ច

ក្រសួងបរិស្ថានជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចគ្រប់គ្រងការវាយតំលៃហេតុប៉ះពាល់បរិស្ថានទាំងអស់។

អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានមានសមត្ថកិច្ចត្រួតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងចេញលិខិតអនុញ្ញាតនានាពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បន្ទាប់ពីមានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានមានសមត្ថកិច្ចតាមដាន ត្រួតពិនិត្យ ធ្វើអធិការកិច្ចអង្កេត ស្រាវជ្រាវ ណែនាំ និងចាត់វិធានការដោយខ្លួនឯង ឬដោយសហការជាមួយភាគីពាក់ព័ន្ធ ចំពោះគម្រោងនិងសកម្មភាពគ្រប់ប្រភេទលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ចំពោះរាល់សកម្មភាព និងគម្រោងដែលទទួលបានការឯកភាពជាមុនពីរាជរដ្ឋាភិបាល ឬមានអាជ្ញាប័ណ្ណ សេចក្តីសម្រេច ដីកាសម្រេច ដែលចេញដោយស្ថាប័ន ក្រសួង អង្គភាពរដ្ឋអាជ្ញាធរខេត្ត/រាជធានីម្ចាស់គម្រោងនៅតែមានកាតព្វកិច្ចត្រូវគោរពតាមកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានជាមួយនឹងក្រសួងបរិស្ថានអនុលោមតាមច្បាប់នេះ។

## មាត្រា៩._អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន

អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានគឺជាសេនាធិការផ្ទាល់របស់ក្រសួង បរិស្ថាន។

អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានមានរចនាសម្ព័ន្ធចាត់តាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវបង្កើតឡើងក្រោយពេលច្បាប់នេះចូលជាធរមាន។

## មាត្រា ១០._ភារកិច្ចរបស់អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន

**អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន មានភារកិច្ចដូចខាងក្រោម៖**

- ទទួលបន្ទុកអនុវត្តច្បាប់នេះក្រោមការត្រួតពិនិត្យពីក្រសួងបរិស្ថាន
- ទទួលបន្ទុកជ្រើសរើសគម្រោងដែលស្នើសុំ កំណត់វិសាលភាពនៃគម្រោងនិងល័ក្ខខ័ណ្ឌនៃការប្រតិបត្តិ ពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងឯកសារទាំងអស់ដែលពាក់ព័ន្ធ និងធានាឲ្យមានការចូលរួមជាសាធារណៈ អនុលោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

- ចុះអង្កេតនិងតាមដានរាល់សកម្មភាពគម្រោងទៅតាម ផែនការត្រួតពិនិត្យតាមដាន និងគ្រប់គ្រងបរិស្ថាន ក្រោយពីម្ចាស់គម្រោងទទួលបានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាការគោរពតាមច្បាប់នេះ។

## មាត្រា ១១._ទំនួលខុសត្រូវរបស់ក្រសួងបរិស្ថាន និងការរៀបចំគោលការណ៍ណែនាំ

ក្រសួងបរិស្ថានជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម៖

- បង្កើតគណៈកម្មការជំនាញផ្ទៃក្នុង។
- តែងតាំងសមាជិកនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យ។
- ចេញលិខិតឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិញ្ញាបនប្រតឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- អនុម័តគោលការណ៍ណែនាំស្តីពីលក្ខណៈវិនិច្ឆ័យការជ្រើសរើសគម្រោង។
- កំណត់វិសាលភាពគម្រោង និងល័ក្ខខ័ណ្ឌនៃការប្រតិបត្តិ។
- អនុម័តគោលការណ៍ណែនាំស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន។
- ប្រើប្រាស់ និងអនុវត្តគោលការណ៍ដែលក្រសួងបានឯកភាព និងអនុវត្តកន្លងមកស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន។
- អនុម័តគោលការណ៍ណែនាំស្តីពីការចូលរួមជាសាធារណៈក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- ចេញប្រកាសស្តីពីលក្ខណៈសម្បត្តិ និងការចុះបញ្ជីទីប្រឹក្សានៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- អនុម័តក្របខ័ណ្ឌវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនសម្រាប់គោលការណ៍ណែនាំរបស់ខ្លួនស្តីពីវិធីវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

## មាត្រា ១២._សិទ្ធិ និងភារកិច្ចរបស់មន្ត្រីអធិការកិច្ចអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន[1]

មន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានមានភារកិច្ចដូចខាងក្រោម៖

- ធ្វើអធិការកិច្ចលើការអនុវត្តបទប្បញ្ញត្តិនានាទាក់ទងនឹងល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថាន ច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ។
- ធ្វើអធិការកិច្ចលើការគោរពតាមល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថាន ដូចដែលបានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិ កិច្ចសន្យា ឬស្តង់ដារ និងល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថានដែលពាក់ព័ន្ធ។
- ពិនិត្យកំណត់ត្រា ឯកសារ ទិន្នន័យអេឡិចត្រូនិកស្តីពីការគ្រប់គ្រងបរិស្ថាន និងកំណត់ត្រាដទៃទៀតស្តីពីគម្រោងអភិវឌ្ឍន៍ និងការប្រតិបត្តិគម្រោង ។

[1]មាត្រា ១២នេះអាចដកចេញ ទៅដាក់ក្នុងគោលការណ៍ ប្រសិនបើចាំបាច់។

- តម្រូវឲ្យអ្នករដ្ឋបាល និយោជិត និងភ្នាក់ងារនៃគម្រោងអភិវឌ្ឍន៍ និងការប្រតិបត្តិគម្រោង ផ្តល់នូវរាល់ព័ត៌មាននិង/ឬកំណត់ត្រាទាំងអស់នៃកិច្ចការគ្រប់គ្រងបរិស្ថាន[2]របស់ម្ចាស់គម្រោង។
- មានសិទ្ធិចូលទៅក្នុងទីបរិវេណទីតាំងគម្រោងដើម្បីអនុវត្តសិទ្ធិអំណាចអធិការកិច្ចនៅទីកន្លែងដែលសង្ស័យថាមានអំពើល្មើសច្បាប់ ឬបទប្បញ្ញត្តិស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថានដោយប្រមូលវត្ថុតាង[3]។
- ជួបជាមួយប្រធានក្រុមប្រឹក្សាភិបាល និងអ្នករដ្ឋបាលនៃគម្រោងអភិវឌ្ឍន៍ឲ្យបានយ៉ាងហោចមួយលើកក្នុង១(មួយ) ឆ្នាំ ដើម្បីធ្វើការវាយតំលៃលើការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត។

### មាត្រា ១៣._សិទ្ធិ និងករណីយកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន

អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវអនុវត្តសិទ្ធិ និងបំពេញករណីយកិច្ច តាមការចាត់តាំងរបស់ក្រសួងបរិស្ថាន ដូចមានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំ។

## ជំពូកទី៤
## កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ(4)

### មាត្រា ១៤._ ការជ្រើសរើសគម្រោង

ការជ្រើសរើសគម្រោងត្រូវបានតម្រូវសម្រាប់រាល់គម្រោងអភិវឌ្ឍន៍ទាំងអស់ សម្រាប់កំណត់ប្រភេទគម្រោងដែលត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។ ការជ្រើសរើសនេះត្រូវអនុលោមតាមតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យដោយឡែក។

ចំពោះរាល់គម្រោងអភិវឌ្ឍន៍ដែលនៅក្រៅឧបសម្ព័ន្ធនៃអនុក្រឹត្យខាងលើ ហើយអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានយល់ឃើញថាមានហេតុប៉ះពាល់ដល់បរិស្ថាននិងសង្គម នោះអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវធ្វើការកំណត់សញ្ញាណនៃហេតុប៉ះពាល់ ដោយសារទីតាំងនៃគម្រោងនៅក្បែរតំបន់រសើបផ្នែកបរិស្ថាន[5] ដើម្បីតម្រូវឲ្យគម្រោងនោះធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

---

[2]សូមមើល សេចក្តីព្រាងរបស់ក្រសួងបរិស្ថាន មាត្រា ៣៨ និង៣៩ ។

[3]សូមមើល សេចក្តីព្រាងរបស់ក្រសួងបរិស្ថាន មាត្រា ៣៨-៣៩ ។

[4]សម្រាប់ជំពូកនេះ ច្បាប់គូសបញ្ជាក់ពីកិច្ចដំណើរការដ៏ទូលំទូលាយដែលត្រូវអនុវត្តតាម។ ចំណុចពិស្តារមាននៅក្នុងគោលការណ៍ណែនាំពាក់ព័ន្ធ ~~ឧបសម្ព័ន្ធទី ១, ៤, ៥, ៧ និង ៨។ ឧបសម្ព័ន្ធទាំងនេះ~~ ដែលគួរត្រូវបានអនុម័ត ក្នុងពេលតែមួយដូចច្បាប់នេះដែរ។ ជាងនេះទៀត មានគោលការណ៍ណែនាំបច្ចេកទេស ដែលក្រសួងបរិស្ថានអាចអនុម័តដើម្បីជួយដល់កិច្ចដំណើរការវាយតំលៃ IEE, EIA និងEMP។

[5]គម្រោងដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ រួមមានគម្រោងនានាដែលតម្រូវឲ្យមាននូវ EIA។ ប្រសិនបើគម្រោងមួយតម្រូវឲ្យមាន EIA វានឹងមិនត្រូវបានតម្រូវឲ្យធ្វើ IEE ឡើយ។ ទោះបីជា IEE អាចមានតំលៃតាមការសមស្រប អ្នកស្នើគម្រោងនឹងអាចប្រើវាដើម្បីពិនិត្យគម្រោងនេះបាន។

ចំពោះគម្រោងដែលពុំតម្រូវឲ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន អគ្គនាយកដ្ឋានវាយ តំលៃហេតុប៉ះពាល់បរិស្ថានអាចតម្រូវឲ្យម្ចាស់គម្រោងចុះកិច្ចសន្យាការពារបរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន អនុលោមតាមការជ្រើសរើសគម្រោងរបស់អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

## មាត្រា ១៥._ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង នឹងត្រូវបានតម្រូវសម្រាប់៖

១. គម្រោងនានាដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ។

២.គម្រោងនានាដូចមានរៀបរាប់ ដែលបានរៀបចំជាកិច្ចសន្យាការពារបរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ហើយដែលសេចក្ដីសម្រេចរបស់ក្រសួងបរិស្ថានក្រោមមាត្រានោះតម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង។

នៅពេលដែលគម្រោងដែលបានស្នើឡើង ត្រូវបានតម្រូវឲ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង អ្នកស្នើគម្រោងនឹងធ្វើសេចក្ដីព្រាងល័ក្ខខ័ណ្ឌការងារដោយអនុលោមតាម បទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថានស្ដីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ក្រសួងបរិស្ថានទទួលខុសត្រូវ ក្នុងការចេញល័ក្ខខ័ណ្ឌការងារស្ដាពរសម្រាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ដោយអនុលោមតាមគោលការណ៍ណែនាំដែលចេញដោយក្រសួងបរិស្ថាន។

ខ្លឹមសារ និងទម្រង់ទូទៅ និងតាមផ្នែកសម្រាប់រៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

## មាត្រា ១៦._ការពិចារណាលើការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង អនុលោមតាមនីតិវិធី ដែលមានចែងក្នុងគោលការណ៍ណែនាំចេញដោយក្រសួងបរិស្ថាន ក្នុងរយៈពេល៦០(ហុកសិប) ថ្ងៃចាប់ពីពេលទទួលបានរបាយការណ៍នោះ។[6]

***សេចក្ដីសម្រេចធ្វើឡើងដោយក្រសួងបរិស្ថាន ក្រោមមាត្រានេះ គឺសេចក្ដីសម្រេច៖***

១. គម្រោងត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន

---

[6]បញ្ហារយៈពេលធ្វើសេចក្ដីសម្រេចដោយក្រសួងបរិស្ថានគឺជាការសំខាន់ណាស់។ វាច្បាស់ថា រយៈពេលបច្ចុប្បន្នខ្លីណាស់។ PRC អនុញ្ញាត ៩០ ថ្ងៃសម្រាប់ការវាយតម្លៃលើ EIA។ ប៉ុន្តែ គេមានសមត្ថភាពវាយតម្លៃ។ PRC មាត្រា ២២ អនុញ្ញាត ៦០ ថ្ងៃគិតចាប់ពីបានទទួលរបាយការណ៍ EIA។ រយៈពេលនេះនឹងទុក ៣០ ថ្ងៃសម្រាប់គណៈកម្មាធិការត្រួតពិនិត្យជំនាញធ្វើការពិនិត្យ EIA និង ៣០ ថ្ងៃទៀតសម្រាប់ក្រសួងបរិស្ថានពិនិត្យរបាយការណ៍នៃគណៈកម្មាធិការនិងមិតយោបល់ពីសាធារណៈជន និងក្រសួងដទៃទៀត។

២. គម្រោងត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន
៣. ផែនការគ្រប់គ្រងបរិស្ថាន
៤. គម្រោងត្រូវមានកិច្ចសន្យាការពារបរិស្ថាន។

## មាត្រា ១៧._ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវបានតម្រូវសម្រាប់៖

១. គម្រោងនានាដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ។

២.គម្រោងនានា ដែលបានរៀបចំវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង[7] ហើយដែលសេចក្តីសម្រេចរបស់ក្រសួងបរិស្ថានក្រោមមាត្រានោះ តម្រូវឲ្យមាន ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

នៅពេលដែលគម្រោងស្នើសុំត្រូវបានតម្រូវឲ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ អ្នកស្នើគម្រោងនឹងធ្វើសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថានស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ក្រសួងបរិស្ថានទទួលខុសត្រូវ ក្នុងការចេញល័ក្ខខ័ណ្ឌការងារស្ថាពរ សម្រាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដោយអនុលោមតាមគោលការណ៍ណែនាំដែលចេញដោយក្រសួងបរិស្ថាន។

ខ្លឹមសារ និងទម្រង់ទូទៅ និងតាមផ្នែកសម្រាប់រៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

## មាត្រា១៨._ រូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន

គុណសម្បត្តិ និងលក្ខណៈវិនិច្ឆ័យរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិក្នុងការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថានហើយត្រូវចុះបញ្ជីនៅក្រសួងបរិស្ថាន មុនពេលធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន[8]។

[7]ទាំងនេះគឺជាគម្រោងដែលតម្រូវឲ្យមាន IEE ហើយបន្ទាប់ពីការត្រួតពិនិត្យ ក្រសួងបរិស្ថានកំណត់ថាគម្រោងត្រូវមាន EIA។

[8]គុណសម្បត្តិទាំងនេះចាំបាច់ត្រូវមាននៅក្នុងគោលការណ៍ណែនាំ ដែលបង្កើតឡើងដោយក្រសួងបរិស្ថាន និងពីផ្នែកមួយនៃគោលការណ៍ណែនាំ។

**មាត្រា១៩._ ខ្លឹមសារ និងទម្រង់ទូទៅនៃរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ**[9]

ក្រោយពេលបញ្ចប់ល័ក្ខខ័ណ្ឌការងារអ្នកស្នើគម្រោងត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញមួយដោយអនុលោមតាមគោលការណ៍ណែនាំ។

របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក៏ត្រូវបញ្ចូលផងដែរនូវផែនការគ្រប់គ្រងបរិស្ថានលម្អិត ផ្អែកលើហេតុប៉ះពាល់បរិស្ថាន និងសង្គម និងការរចនាគម្រោងអភិវឌ្ឍន៍។

ប្រសិនបើមាននូវទិន្នន័យមូលដ្ឋាននៅក្នុងវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញដែលទទួលបានការឯកភាពមួយផ្សេងទៀត អ្នកស្នើគម្រោងត្រូវបញ្ជូនទិន្នន័យនេះទៅក្រសួងបរិស្ថាន។

**មាត្រា ២០._ ការបង្កើតគណៈកម្មការត្រួតពិនិត្យជំនាញ**

- ក្រសួងបរិស្ថាន ត្រូវទទួលខុសត្រូវបង្កើតគណៈកម្មការត្រួតពិនិត្យជំនាញមួយដោយអនុលោមតាមតារាងពេលវេលា និងកិច្ចដំណើរការនានាដែលបានដាក់ចេញនៅក្នុងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន[10]។
- រាល់គម្រោងអភិវឌ្ឍន៍នានាដែលតម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ចាំបាច់ត្រូវមានគណៈកម្មការត្រួតពិនិត្យជំនាញមួយដែលមានសមាជិកមកពីមន្ត្រីក្រសួងបរិស្ថាន ក្រសួង/ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញឯករាជ្យ ដែលមានគុណសម្បត្តិនិងបទពិសោធន៍សមស្របក្នុងការពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។
- ក្រសួងបរិស្ថានត្រូវជ្រើសរើស និងអញ្ជើញអ្នកជំនាញការជាតិ និង/ឬអន្តរជាតិឲ្យធ្វើជាសមាជិកគណៈកម្មការត្រួតពិនិត្យជំនាញ ដែលត្រូវបានបង្កើតឡើងជាពិសេសដើម្បីពិនិត្យទិដ្ឋភាពបច្ចេកទេសនៃរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។
- សមាជិកគណៈកម្មការត្រួតពិនិត្យជំនាញត្រូវបានជ្រើសរើសពីគម្រោងមួយទៅគម្រោងមួយ។ សមាជិកទាំងឡាយត្រូវបានទូទាត់ប្រាក់កម្រៃសម្រាប់ការបម្រើការងាររបស់ខ្លួនដោយផ្អែកលើការព្រមព្រៀងរវាងក្រសួងបរិស្ថាន និងសមាជិកដោយអនុលោមតាមគោលការណ៍ណែនាំអំពីថ្លៃ និងបន្ទុកសេវាបរិស្ថាន។ ចំណាយទាំងនេះគឺជាផ្នែកនៃថ្លៃដែលបានគិតពីអ្នកស្នើសុំគម្រោង សម្រាប់ការវាយតំលៃរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

---

[9]ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ EIA និងគោលការណ៍ណែនាំទូទៅ គួរត្រូវបានបញ្ចូលទៅក្នុងគោលការណ៍ណែនាំ។ បញ្ហាគឺថាតើឯកសារនេះគួរតែជាឯកសាររបស់ក្រសួង ឬជាច្បាប់។

[10]គេបានសំណូមពរឲ្យបញ្ចូលកិច្ចដំណើរការនៃក្រុមអ្នកជំនាញ និងរយៈពេលទៅក្នុងអនុក្រឹត្យ។

## មាត្រា ២១._ ការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន [11]

- ក្រសួងបរិស្ថានមានភារកិច្ចចម្បងធ្វើការពិនិត្យ និងពិចារណាលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយផ្អែកលើមតិយោបល់របស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ មតិយោបល់សាធារណៈ និងគណៈកម្មការត្រួតពិនិត្យជំនាញដែលបានស្នើឡើង។

- ក្រសួងបរិស្ថាន ត្រូវពិចារណាលើរបាយការណ៍របស់គណៈកម្មការត្រួតពិនិត្យជំនាញមុនពេលចេញវិញ្ញាបនប្រតងកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលសម្រាប់ផ្តល់ការឯកភាពដល់គម្រោងអភិវឌ្ឍន៍។[12]

- ក្រសួងបរិស្ថានទទួលខុសត្រូវធានានូវដំណើរការសវនាការមួយ ប្រកបដោយភាពយុត្តិធម៌ ដើម្បីផ្តល់លទ្ធភាពឲ្យមានការចូលរួមជាសាធារណៈនិងត្រូវអញ្ជើញក្រសួង ឬក្រសួង/ស្ថាប័នពាក់ព័ន្ធតាមវិស័យនានា សង្គមស៊ីវិលនិងអ្នកដែលទទួលរងការប៉ះពាល់ឲ្យចូលរួមសវនាការទាំងនោះ ព្រមទាំងផ្តល់មតិយោបល់ចំពោះគម្រោងដែលបានស្នើឡើងនោះ។

- ក្រសួងបរិស្ថាន គឺជាទីភ្នាក់ងារដឹកនាំ និងសម្របសម្រួលជាមួយនឹងក្រសួង ឬទីភ្នាក់ងារតាមវិស័យដែលពាក់ព័ន្ធនានា រួមទាំងបណ្តាភាគីទាំងឡាយដែលអាចនឹងទទួលរងហេតុប៉ះពាល់ដោយផ្ទាល់ឬប្រយោលពីគម្រោង ដើម្បីឲ្យចូលរួមសវនាការដែលបានគ្រោងទុក។

- ដោយផ្អែកលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ការបង្ហាញជាផ្លូវការដោយអ្នកស្នើគម្រោង និងតាមរយៈមតិ យោបល់លាយលក្ខណ៍អក្សររបស់គណៈកម្មការត្រួតពិនិត្យជំនាញ ព្រមទាំងមតិយោបល់ពីការពិគ្រោះយោបល់ពីការចូលរួមជាសាធារណៈរបស់បណ្តាក្រសួង ឬស្ថាប័នពាក់ព័ន្ធ នោះក្រសួងបរិស្ថានត្រូវពិចារណាលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ និងកំណត់នូវសកម្មភាពមួយចំនួនដូចខាងក្រោម ដោយពិចារណាលើលក្ខណៈ ទំហំ និងទីតាំងនៃគម្រោងអភិវឌ្ឍន៍៖

១.ចេញនូវវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានសម្រាប់របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងផែនការគ្រប់គ្រងបរិស្ថាន។

២. បដិសេធរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

- នៅពេលក្រសួងបរិស្ថានចេញវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានក្រសួងត្រូវភ្ជាប់ល័ក្ខខ័ណ្ឌផ្សេងៗលើវិញ្ញាបនបត្រឯកភាពលើរបាយការណ៍នេះ។
- នៅពេលក្រសួងបរិស្ថានបដិសេធរបាយការណ៍នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានក្រសួងបរិស្ថានត្រូវបញ្ជាក់ពីហេតុផលនៃសេចក្តីសម្រេចរបស់ខ្លួន។

[11] គេដឹងថា ក្រសួងបរិស្ថានមិនឯកភាពលើគម្រោងឡើយ។ បច្ចុប្បន្ននេះ គ្រប់គម្រោងទាំងអស់ត្រូវបានឯកភាពដោយរដ្ឋាភិបាល។ គោលបំណងនៃវិញ្ញាបនបត្របញ្ជាក់ពីអនុលោមភាពផ្អែកបរិស្ថាន គឺទទួលបាននូវឯកសារមួយដែលមាននូវរាល់ល័ក្ខខ័ណ្ឌពាក់ព័ន្ធទាំងអស់ ដែលមានជាប់ជាមួយនឹងការឯកភាពនោះ រួមទាំងផែនការគ្រប់គ្រងបរិស្ថានផងដែរ។

[12] មានតែគម្រោងដែលតម្រូវឲ្យមាន EIA ប៉ុណ្ណោះ ដែលនឹងត្រូវមានការតែងតាំងក្រុមអ្នកត្រួតពិនិត្យជំនាញមួយក្រុម។ តើប្រការនេះត្រឹមត្រូវដែរឬទេ?ក្នុងករណីណាមួយដែលរាល់គម្រោងទាំងអស់ នឹងត្រូវបានបដិសេធ ឬទទួលបាននូវ ECC។

- ក្រសួងបរិស្ថាន ត្រូវផ្ញើសេចក្តីសម្រេចរបស់ខ្លួនរួមទាំងល័ក្ខខ័ណ្ឌ ឬហេតុផលទៅឲ្យម្ចាស់គម្រោង ក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ ក្រសួងបរិស្ថានត្រូវផ្តល់សំណៅចម្លងមួយច្បាប់នៃសេចក្តីសម្រេចរបស់ខ្លួនដល់សាធារណជន នៅលើគេហទំព័ររបស់ខ្លួន និងតាមរយៈការបោះពុម្ពផ្សាយតាមសារព័ត៌មានក្នុងតំបន់ ឬថ្នាក់ជាតិ។

## មាត្រា ២២._ ការចេញវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន

ម្ចាស់គម្រោងដែលត្រូវបានតម្រូវឲ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬនីតិវិធីវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវទទួលបាននូវវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានជាមុនសិន មុននឹងអ្នកស្នើគម្រោងចាប់ផ្តើមដំណើរការក្នុងដំណាក់កាលមុនសាងសង់ ឬដំណាក់កាលសាងសង់។

គម្រោងអភិវឌ្ឍន៍ណាដែលគ្មានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវផ្អាកសកម្មភាពទាំងអស់ រហូតទាល់តែក្រសួងបរិស្ថានបានចេញវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ក្រសួងបរិស្ថានត្រូវចេញវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការ ក្រោយពីបានពិនិត្យ និងឯកភាពលើឯកសារវាយតំលៃបរិស្ថានត្រឹមត្រូវចំពោះពល់គម្រោងអភិវឌ្ឍន៍ដែលទទួលបានការកិច្ចព្រមព្រៀងសម្បទានពីរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។ វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការត្រូវបានភ្ជាប់ជាមួយផែនការគ្រប់គ្រងបរិស្ថានលម្អិតដែលជាភស្តុតាងសម្រាប់ការអនុញ្ញាតចំពោះគម្រោង និងការអនុវត្តកាតព្វកិច្ចរបស់ភាគីអ្នកស្នើគម្រោងនិងក្រសួងបរិស្ថាន។

ក្រសួងបរិស្ថានមិនអាចចេញវិញ្ញាបនបត្រឯកភាពរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុនពេលមិនទាន់បានទទួលមតិយោបល់ជាលាយលក្ខណ៍អក្សរពីសមាជិកទាំងអស់នៃគណៈកម្មការត្រួតពិនិត្យជំនាញនោះទេ។ មតិយោបល់ និងល័ក្ខខ័ណ្ឌដែលកំណត់ដោយសមាជិកនៃគណៈកម្មការត្រួតពិនិត្យជំនាញ ត្រូវដាក់បញ្ចូលជាល័ក្ខខ័ណ្ឌក្នុងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលចេញដោយក្រសួងបរិស្ថាន។

វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានមានសុពលភាពសម្រាប់រយៈពេលមិនលើសពី៥(ប្រាំ) ឆ្នាំឡើយ[13]។

ផែនការគ្រប់គ្រងបរិស្ថានលម្អិតសម្រាប់គម្រោងត្រូវភ្ជាប់នឹងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយត្រូវចងកាតព្វកិច្ចផ្លូវច្បាប់លើភាគីទាំងពីរ។

ក្រសួងបរិស្ថាន ត្រូវផ្ញើវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានទៅឲ្យម្ចាស់គម្រោង ហើយផ្ញើសំណៅមួយច្បាប់ឲ្យទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងទៅឲ្យក្រសួង ឬស្ថាប័នអនុម័តគម្រោង។

[13]សូមមើលមាត្រា ២៤ នៃច្បាប់ PRC EIA របស់ប្រទេសចិន។ ក្រោយរយៈពេលប្រាំឆ្នាំ មានឱកាសបន្តវិញ្ញាបនបត្រឯកភាពការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ម្ចាស់គម្រោងត្រូវទូទាត់រាល់ថ្លៃ និងបន្ទុកសេវាទាំងអស់ដែលបានកំណត់ដោយក្រសួងបរិស្ថាន មុនពេលវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានចូលជាធរមាន។

ក្រសួងបរិស្ថានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់គម្រោងអំពីសេចក្តីសម្រេចរបស់ក្រសួង។ សំណៅមួយច្បាប់នៃសេចក្តីសម្រេចនេះត្រូវបង្ហោះលើគេហទំព័ររបស់ក្រសួងបរិស្ថាន ហើយសំណៅមួយច្បាប់នៃវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវបង្ហោះលើគេហទំព័ររបស់ក្រសួងបរិស្ថាន ព្រមជាមួយនឹងផែនការគ្រប់គ្រងបរិស្ថាន។

**មាត្រា ២៣._ការពិចារណាលើគម្រោងអភិវឌ្ឍន៍ដែលស្ថិតនៅតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ**

មុននឹងសម្រេចផ្តល់នូវលិខិតអនុញ្ញាតឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍ដែលមានទីតាំងស្ថិតនៅតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ក្រសួងបរិស្ថាន សមាជិកនៃគណៈកម្មការត្រួតពិនិត្យជំនាញ ឬអ្នកពាក់ព័ន្ធក្នុងការចូលរួមក្នុងការសម្រេច ត្រូវធ្វើការយកចិត្តទុកដាក់ និងពិចារណាខ្ពស់ចំពោះគម្រោងនោះដើម្បីបញ្ចៀសហេតុប៉ះពាល់ជាអវិជ្ជមានដូចជាទំនៀមទំលាប់ ប្រពៃណី វប្បធម៌ ការប្រកបរបរចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ ដល់សហគមន៍ជនជាតិភាគតិច។[14]

## ជំពូកទី៥
## ការចូលរួមជាសាធារណៈ

**មាត្រា ២៤._កិច្ចដំណើរការចូលរួមជាសាធារណៈ[15]**

គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ គឺដើម្បីធានាថា អ្នកដែលទទួលរងហេតុប៉ះពាល់ និងភាគីពាក់ព័ន្ធ បានទទួលដំណឹងគ្រប់ជ្រុងជ្រោយអំពីគម្រោង ព្រមទាំងមានឱកាសចូលរួមក្នុងកិច្ចពិភាក្សា និងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងគម្រោង រួមទាំងឱកាសចូលរួមក្នុងការអង្កេតតាមដានគម្រោង។ ការពិពណ៌នាពីកិច្ចដំណើរការផែនការពិគ្រោះយោបល់ និងអ្នកចូលរួមក្នុងកិច្ចដំណើរការនេះត្រូវដាក់បញ្ចូលក្នុងល័ក្ខខ័ណ្ឌការងារនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

---

[14]គោលការណ៍ណែនាំនឹងត្រូវបានរៀបចំដោយក្រសួងបរិស្ថាន សម្រាប់ដោះស្រាយបញ្ហាពិសេសៗ អំពីក្រុមជនជាតិភាគតិច។

[15]សូមមើលឧទាហរណ៍ ច្បាប់ស្តីពីកិច្ចការពារបរិស្ថានរបស់ប្រទេសកម្ពុជា មាត្រា ១ អនុក្រឹត្យស្តីពីកិច្ចដំណើរការ EIA របស់ប្រទេសកម្ពុជា ឆ្នាំ១៩៩៩ និងច្បាប់ PRC EIA ឆ្នាំ២០០៣ មាត្រា ៥ រួមទាំងវិធានការព្រាង PRC SEPA សម្រាប់ការចូលរួមជាសាធារណៈ បទប្បញ្ញត្តិស្តីពីហេតុប៉ះពាល់លើបរិស្ថាននៃផែនការ ឆ្នាំ២០០៩ ផងដែរ។

ម្ចាស់គម្រោងត្រូវដាក់បញ្ចូលការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈទៅក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៅដំណាក់កាលរៀបចំផែនការគម្រោង ដើម្បី៖

- កំណត់ផ្នែកដែលមានសារៈសំខាន់ផ្នែកវប្បធម៌ និងសង្គម។
- ប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធ និងដាក់បញ្ចូលមតិយោបល់ទាំងនោះទៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេច។
- ពិនិត្យគម្រោងស្នើសុំ និងពន្យល់ពីហេតុប៉ះពាល់សង្គម និងបរិស្ថាន។
- ពិចារណាជម្រើសដទៃទៀត និងវិធានការកាត់បន្ថយហេតុប៉ះពាល់នានា។

ម្ចាស់គម្រោងត្រូវធានាថា រាល់អ្នកដែលទទួលរងហេតុប៉ះពាល់ រដ្ឋបាលមូលដ្ឋាន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតត្រូវទទួលបានព័ត៌មានអំពីគម្រោងនិងទទួលបានឱកាសក្នុងការចូលរួមយ៉ាងពេញលេញ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ។

កិច្ចប្រជុំត្រូវបានរៀបចំដោយម្ចាស់គម្រោង ដោយពិគ្រោះយោបល់ជាមួយនឹងក្រសួងបរិស្ថាន និងក្រសួង ឬស្ថាប័នពាក់ព័ន្ធ ក្នុងអំឡុងពេលនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

រាល់ការចំណាយដែលពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាសាធារណៈ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង។

នីតិវិធីនៃការចូលរួមជាសាធារណៈនៅក្នុងដំណាក់កាលសិក្សាពិគ្រោះយោបល់ ការ ពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការអង្កេតតាមដានគម្រោងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

### មាត្រា២៥._របាយការណ៍ស្តីពីការចូលរួមជាសាធារណៈ[16]

ការចូលរួមជាសាធារណៈទាំងអស់ត្រូវកត់ត្រាទុក និងពិចារណាដោយម្ចាស់គម្រោងក្នុងដំណាក់កាលរៀបចំផែនការ និងដំណាក់កាលអនុវត្តលើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ម្ចាស់គម្រោងត្រូវរាយការណ៍អំពីសេចក្តីលំអិតនៃហេតុប៉ះពាល់របស់សាធារណជន និងការទទួលយក ឬបដិសេធពីសំណើរបស់សាធារណជន។

ប្រសិនបើម្ចាស់គម្រោងបដិសេធពីសំណើរបស់សាធារណជនម្ចាស់គម្រោងត្រូវផ្តល់ហេតុផលបដិសេធទាំងនោះក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានឲ្យបានច្បាស់។

### មាត្រា ២៦._ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ

កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវបានយកមកប្រើ ដើម្បីកំណត់វិធានការលើកកម្ពស់ជីវភាព និងជួយដល់អ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង។

កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវធានាថា អ្នកដែលទទួលរងហេតុប៉ះពាល់ បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយហេតុប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឲ្យបានកម្រិតអប្បបរមា ដើម្បីធានាថា សំណងលើការបាត់បង់ទ្រព្យសម្បត្តិត្រូវបានដោះស្រាយ

[16] នេះឆ្លុះបញ្ចាំងពីបទប្បញ្ញត្តិនៃមាត្រា ២១ នៃច្បាប់ EIA របស់ PRC

ដោយយុត្តិធម៌សមស្របនិងទទួលយកបានតាមតម្លៃទីផ្សារហើយវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានមានលក្ខណៈ ត្រឹមត្រូវ។

នីតិវិធីនៃការផ្លាស់ប្តូលំនៅថ្មី និងដោះស្រាយសំណងដល់សហគមន៍ដែលទទួលរងហេតុប៉ះពាល់ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទ និងនីតិវិធីនៃការទូទាត់សំណងការខូចខាតដល់សហគមន៍ទទួលរងហេតុប៉ះពាល់ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវធានាថា សហគមន៍ដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង មានលទ្ធភាពផ្តល់ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន។

### មាត្រា ២៧._សិទ្ធិទទួលបានព័ត៌មាន

ក្រសួងបរិស្ថានត្រូវធានាថា ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងឬការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងឯកសារពាក់ព័ន្ធទាំងអស់ រាប់ទាំងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

ឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈ មានបង្ហោះលើគេហទំព័រសាធារណៈរបស់ក្រសួងបរិស្ថាន។

ថ្លៃចំណាយលើការផ្សព្វផ្សាយឯកសារជាសាធារណៈ រាប់ទាំងគេហទំព័រ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង។

ក្រសួងបរិស្ថានត្រូវកំណត់គោលការណ៍ណែនាំបន្ថែមស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន។

## ជំពូកទី ៦
## ការវាយតំលៃហេតុប៉ះពាល់បរិស្ថានគម្រោងដែលកំពុងដំណើរការ

### មាត្រា ២៨._គម្រោងដែលកំពុងដំណើរការ

ក្រសួងបរិស្ថាននឹងពិគ្រោះយោបល់ជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលការណ៍ណែនាំសម្រាប់ប្រភេទគម្រោង ដែលមិនបានអនុវត្តការវាយតំលៃហេតុប៉ះពាល់បរិស្ថានដើម្បីតម្រូវឲ្យម្ចាស់គម្រោងទាំងនោះរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថាន។

គោលការណ៍ណែនាំត្រូវបោះពុម្ពផ្សព្វផ្សាយក្នុងរយៈពេល ៣(បី) ខែ គិតចាប់ពីពេលច្បាប់ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថានចូលជាធរមាន។

គោលការណ៍ណែនាំត្រូវផ្អែកលើគោលការណ៍ណែនាំស្តីពីការជ្រើសរើសគម្រោង។

ម្ចាស់គម្រោង មានរយៈពេល៦(ប្រាំមួយ) ខែ ដើម្បីគោរពតាមល័ក្ខខ័ណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះ

ពាល់បរិស្ថានពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថានឲ្យបានចប់ហើយដាក់ឯកសារទៅក្រសួងបរិស្ថានដើម្បីពិនិត្យ ផ្តល់យោបល់ និងឯកភាព។

ផែនការគ្រប់គ្រងបរិស្ថានដែលតម្រូវ ត្រូវបញ្ជាក់លម្អិតនូវរាល់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានស្នើឡើងដើម្បីកាត់បន្ថយឲ្យបានកម្រិតអប្បបរមានូវហេតុប៉ះពាល់បរិស្ថាននិងសង្គម ដើម្បីធានាបាននូវគុណភាពបរិស្ថាន និងការបំពេញបានតាមស្តង់ដារបរិស្ថាន។

ថវិកាលំអិតអំពីការប៉ាន់ស្មាននៃការចំណាយត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោងដោយត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

## ជំពូកទី ៧
## ផែនការគ្រប់គ្រងបរិស្ថាននិងការអង្កេតតាមដានគម្រោង

### មាត្រា ២៩._អាជ្ញាធរត្រួតពិនិត្យ

អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត ជាអាជ្ញាធរត្រួតពិនិត្យលើផែនការគ្រប់គ្រងបរិស្ថាន និងអង្កេតតាមដានសកម្មភាពអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ដោយសហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និង អ្នកពាក់ព័ន្ធ។

### មាត្រា៣០._ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថានត្រូវរៀបចំដោយម្ចាស់គម្រោង។

ផែនការគ្រប់គ្រងបរិស្ថានត្រូវដាក់បញ្ចូលក្នុងល័ក្ខខ័ណ្ឌតម្រូវនៃការការពារការកាត់បន្ថយការឃ្លាំមើល និងការគ្រប់គ្រង ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

រាល់គម្រោងអភិវឌ្ឍន៍ ដែលទទួលបានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវគោរពតាមល័ក្ខខ័ណ្ឌ និងខ្លឹមសារ ដែលមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន ព្រមទាំងល័ក្ខខ័ណ្ឌដែលមានចែងក្នុងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

### មាត្រា ៣១._ការគ្រប់គ្រង និងឃ្លាំមើលបរិស្ថានដោយម្ចាស់គម្រោង[17]

រាល់គម្រោងអភិវឌ្ឍន៍ និងអ្នកប្រតិបត្តិការគម្រោង ត្រូវបង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុងដែលត្រូវធានាឲ្យមាននូវនីតិវិធី និងវិធីសាស្ត្រឃ្លាំមើលដោយខ្លួនឯង ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន។

[17]ព័ត៌មានលម្អិតអំពីទម្រង់ផែនការគ្រប់គ្រងបរិស្ថាន មាននៅក្នុងគោលការណ៍ណែនាំ។

ក្នុងករណីហេតុប៉ះពាល់បរិស្ថានមានកម្រិតលើសពីស្តង់ដារកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ក្រសួងបរិស្ថានតម្រូវឲ្យចាត់វិធានការកែតម្រូវហេតុប៉ះពាល់ភ្លាមៗ ឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន។

ផែនការគ្រប់គ្រងបរិស្ថានដែលបានកែតម្រូវរួច និងកម្មវិធីឃ្លាំមើល ត្រូវទទួលបានការឯកភាពពីក្រសួងបរិស្ថាន ហើយរយៈពេលត្រូវកំណត់ឡើងសារជាថ្មី ដើម្បីធ្វើការកែតម្រូវ ឬកែលម្អចាំបាច់ ដោយត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគីពាក់ព័ន្ធ។

ថ្លៃចំណាយទាំងអស់ក្នុងការកែតម្រូវ ឬកែលម្អវិធានការកាត់បន្ថយហេតុប៉ះពាល់ និងកម្មវិធីឃ្លាំមើលគម្រោង ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង។

ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់០៣ខែម្តង ហើយបញ្ជូនមកអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់។ អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានមានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផលនៃការអង្កេតតាមដានរបស់ម្ចាស់គម្រោង។

## មាត្រា ៣២._បណ្តឹងដែលធ្វើឡើងដោយអ្នកទទួលរងហេតុប៉ះពាល់ពីគម្រោង

អ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង ត្រូវមានសិទ្ធិទទួលបានព័ត៌មានស្តីពីហេតុប៉ះពាល់អវិជ្ជមានលើជីវិតរស់នៅ ទ្រព្យសម្បត្តិ និងសិទ្ធិទទួលបានក្នុងការប្រើប្រាស់ធនធានធម្មជាតិ និងជីវភាពរស់នៅនិងសិទ្ធិទទួលបាននូវព័ត៌មានអំពីស្ថានការណ៍បរិស្ថាននៃគម្រោង និងល័ក្ខខ័ណ្ឌតម្រូវតាមច្បាប់ បទប្បញ្ញត្តិ កិច្ចសន្យា និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

អ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង ត្រូវមានសិទ្ធិរាយការណ៍ពីបញ្ហានិងក្តីកង្វល់បរិស្ថាន និងសង្គមជូនដល់ម្ចាស់គម្រោង និងដាក់បណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ហាទាំងនោះត្រូវដោះស្រាយដោយគណៈកម្មការថ្នាក់ក្រោម និងអាចបន្តមកគណៈកម្មការអន្តរក្រសួង ដែលបង្កើតឡើងជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន។

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវឆ្លើយតបចំពោះបណ្តឹង ឬញាតិហើយដោះស្រាយបញ្ហាបរិស្ថាន និងសង្គមដែលពាក់ព័ន្ធ តាមពេលវេលាកំណត់សមស្រប និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង។

## មាត្រា ៣៣._ការឃ្លាំមើលដោយស្ថាប័នខាងក្រៅ (សវនករបរិស្ថានខាងក្រៅ)[18]

គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រតិបត្តិការនៃគម្រោង ត្រូវធ្វើសវនកម្មដោយសវនករបរិស្ថានខាងក្រៅ ដូចមានចែងក្នុងកិច្ចសន្យារបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដែលត្រូវ៖

- ជួយជ្រោមជ្រែងក្នុងការកត់ត្រាកំណត់ត្រាបរិស្ថានឲ្យបានត្រឹមត្រូវ និងពេញលេញ។

[18] គោលការណ៍អេក្វាទ័រ និងស្តង់ដារអនុវត្តរបស់ IFIs តម្រូវឲ្យមានការជួលសវនករពីខាងក្រៅដោយអ្នកស្នើគម្រោង ដើម្បីចូលរួមក្នុងក្រុមការងារជំនួយបច្ចេកទេសរបស់អ្នកឲ្យខ្ចី ដើម្បីធ្វើសវនកម្មគម្រោងជាទៀងទាត់ និងដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរជូនធនាគារ។

- ផ្ដល់មតិយោបល់សវនកម្មវិជ្ជាជីវៈ ដូចជា របាយការណ៍បរិស្ថានដែលបង្ហាញនូវទិដ្ឋភាពពេញលេញ និងសមស្របអំពីការគ្រប់គ្រងបរិស្ថាននៃគម្រោង ឬការប្រតិបត្តិការរបស់គម្រោង។
- ពិនិត្យភាពគ្រប់គ្រាន់នៃការអនុវត្ត នីតិវិធីនៃការគ្រប់គ្រង និងការឃ្លាំមើលបរិស្ថានផ្ទៃក្នុង ព្រមទាំងការផ្ដល់អនុសាសន៍ដើម្បីកែលម្អ។
- ផ្ដល់ព័ត៌មានអំពីភាពមិនប្រក្រតី និងការខ្វះចន្លោះក្នុងការគ្រប់គ្រងបរិស្ថានផ្ទៃក្នុងរបស់ខ្លួន។

សំណៅមួយច្បាប់នៃរបាយការណ៍សវនកម្ម ដែលធ្វើឡើងដោយសវនករបរិស្ថានខាងក្រៅ ត្រូវប្រគល់ជូនក្រសួងបរិស្ថាន។

## មាត្រា ៣៤._ការបោះពុម្ព និងការផ្សព្វផ្សាយ

គម្រោងអភិវឌ្ឍន៍នីមួយៗត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោង ដូចតទៅះ

- របាយការណ៍រៀងរាល់០៣ (បី) ខែ ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលរាយកាណ៍ពីលទ្ធផលទាំងអស់នៃការអង្កេតតាមដាន ឃ្លាំមើល និងការគ្រប់គ្រងបរិស្ថាន។
- ក្នុងរយៈពេល០៣(បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ដែលដាក់បញ្ចូលមតិយោបល់របស់សវនករស្ដីពីបរិស្ថាន។
- ផ្ដល់សំណៅរបាយការណ៍បរិស្ថានប្រចាំឆ្នាំនៃគម្រោងដល់សាធារណជន តាមការស្នើសុំដោយឥតគិតថ្លៃ។
- ផ្ដល់សំណៅអេឡិចត្រូនិកដែលនឹងត្រូវបង្ហោះលើគេហទំព័រជាសាធារណៈរបស់ក្រសួងបរិស្ថាន និងដោយម្ចាស់គម្រោង នៅលើគេហទំព័រសាធារណៈមួយ។

## មាត្រា៣៥._របាយការណ៍ផ្ញើទៅក្រសួងបរិស្ថាន

គម្រោងអភិវឌ្ឍន៍ ដែលមានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវរៀបចំរបាយការណ៍ប្រចាំខែ និងត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាស និងឆមាស ទៅអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានទាទាក់ទងនឹងការឃ្លាំមើល និងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន។

ម្ចាស់គម្រោងមានកាតព្វកិច្ចត្រូវរាយការណ៍ភ្លាមៗអំពីបញ្ហាបរិស្ថានសំខាន់ដល់អាជ្ញាធរដែលពាក់ព័ន្ធ និងដែលមានទទួលខុសត្រូវ និងដល់សាធារណជន ដើម្បីជៀសវាងហេតុប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬសង្គម។

អ្នកផ្ដល់សេវាបរិស្ថានវិជ្ជាជីវៈនីមួយៗដល់គម្រោងដែលមានវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវផ្ដល់ព័ត៌មានដល់ក្រសួងបរិស្ថាន តាមដែលក្រសួងបរិស្ថានអាចស្នើសុំដោយសមហេតុផលពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោង។

**មាត្រា ៣៦._វិវាទបរិស្ថាននិងសង្គម (នីតិវិធីបណ្តឹងសាធារណៈ)**

ម្ចាស់គម្រោងត្រូវអនុវត្តតាមគោលការណ៍ណែនាំ ដែលបង្កើតឡើងដោយក្រសួងបរិស្ថានស្តីពីការទទួល និងដោះស្រាយបណ្តឹងអំពីបញ្ហាបរិស្ថាន ដែលបង្កឡើងដោយគម្រោង។

ម្ចាស់គម្រោងត្រូវពិគ្រោះយោបល់ជាមួយនឹងក្រសួងបរិស្ថាន ដើម្បីជួយដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាធារណៈ។

ក្នុងការដោះស្រាយបញ្ហា ឬវិវាទបរិស្ថានភាគីពាក់ព័ន្ធទាំងអស់មានសិទ្ធិដោះស្រាយបញ្ហារបស់ខ្លួនតាមរយៈការពិគ្រោះយោបល់ជាមួយនឹងម្ចាស់គម្រោងមុនពេលចាត់វិធានការណាមួយទៅស្ថាប័នរដ្ឋបាលថ្នាក់ជាតិ ឬប្រព័ន្ធតុលាការ។

ម្ចាស់គម្រោងត្រូវមានសៀវភៅកត់ត្រាបណ្តឹងសាធារណៈពីអ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង។

អ្នកដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង ត្រូវបានលើកលែងពីការបង់ថ្លៃសេវារដ្ឋបាល និងផ្លូវច្បាប់ពាក់ព័ន្ធនឹងនីតិវិធីដោះស្រាយ។ នៅពេលដែលបញ្ហាបរិស្ថានត្រូវបានបញ្ជូនទៅតុលាការរាល់ថ្លៃចំណាយផ្លូវច្បាប់ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង។

## ជំពូកទី ៨

## ផ្នែកទី១

## ហេតុប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ

**មាត្រា ៣៧._ការពិចារណាបម្រែបម្រួលអាកាសធាតុនៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន**

រាល់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវវិភាគ និងវាយតំលៃពីសក្តានុពលនៃហេតុប៉ះពាល់ និងភាពងាយរងគ្រោះនៃគម្រោងបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ និងការអភិវឌ្ឍដែលអាចរងនូវអតុល្យភាពដោយសារលក្ខខណ្ឌបរិស្ថានដែលរងការប៉ះពាល់ ដោយរកវិធានការកាត់បន្ថយហានិភ័យដែលអាចកើតឡើងទាំងនេះ សំដៅឈានដល់ការអភិវឌ្ឍសេដ្ឋកិច្ចដែលប្រើកាបូនតិចដែលជាទិសដៅចម្បងនៃការអភិវឌ្ឍបៃតង។

រាល់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវដាក់បញ្ចូលពីការវាយតំលៃហានិភ័យ និងភាពងាយរងគ្រោះនៃបម្រែបម្រួលអាកាសធាតុហើយវិភាគពីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ផែនការឆ្លើយតបបន្ទាន់ និងជម្រើសបច្ចេកវិទ្យាដើម្បីត្រៀមទប់ទល់នឹងហេតុប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ។

បរិមាណនៃការបញ្ចេញកាបូនរបស់គម្រោងអភិវឌ្ឍន៍ត្រូវគណនាដោយប្រើប្រាស់ការវិភាគបញ្ចេញកាបូនទាប និងការប្រើប្រាស់ការផលិតនិងការផ្គត់ផ្គង់ដោយនិរន្តរភាពដោយដាក់បញ្ចូលទៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ[19] ដើម្បីសម្រេចបាននូវការអភិវឌ្ឍបៃតង។

---

[19]បម្រែបម្រួលអាកាសធាតុផ្លាស់ប្តូរក្របខណ្ឌដែលពិចារណាលើតម្រូវការទឹក និងថាមពល។ ម្ចាស់គម្រោងគួរស្វែងរកជម្រើសប្រើប្រាស់ថាមពលកាបូនកម្រិតទាប និងភាពចាំបាច់ក្នុងការកាត់បន្ថយបម្រែបម្រួលទឹកដោយសារអាកាស

## ផ្នែកទី២
## បណ្ដុំនៃហេតុប៉ះពាល់

### មាត្រា ៣៨._ គោលការណ៍ និងវិធីសាស្ត្រនៃបណ្ដុំនៃហេតុប៉ះពាល់

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវវិភាគនិងវាយតំលៃពីបណ្ដុំនៃហេតុប៉ះពាល់ដោយសារគម្រោងនានានៅជុំវិញនៃទីតាំងគម្រោងរបស់ខ្លួន ដែលបង្កើតឲ្យមានហេតុប៉ះពាល់បរិស្ថាន ឬសង្គមធ្ងន់ធ្ងរ។

ការវាយតំលៃបណ្ដុំនៃហេតុប៉ះពាល់ម្ចាស់គម្រោងត្រូវវាយតំលៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គមផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងរបស់ខ្លួន។

ម្ចាស់គម្រោងត្រូវរកវិធានការកាត់បន្ថយបណ្ដុំនៃហេតុហេតុប៉ះពាល់ផ្សេងៗឲ្យដល់កម្រិតអប្បបរមា។

## ផ្នែកទី៣
## ការវាយតំលៃហេតុប៉ះពាល់សុខភាព

### មាត្រា ៣៩._ គោលការណ៍នៃការវាយតំលៃហេតុប៉ះពាល់សុខភាព

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវដាក់បញ្ចូលការវាយតំលៃហេតុប៉ះពាល់សុខភាព ដែលមានដូចជាៈ

- ទិន្នន័យមូលដ្ឋានស្ដីពីសុខភាពនៅក្នុងតំបន់គម្រោង និងរបស់ប្រជាជនដែលរងហេតុប៉ះពាល់។
- ការពិពណ៌នាអំពីហេតុប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់ លំហូរប្រជាជន និងការផ្លាស់ប្ដូរចំពោះបរិស្ថាន។
- វិធានការកាត់បន្ថយហេតុប៉ះពាល់ដើម្បីកាត់បន្ថយ ឬលុបបំបាត់ហេតុប៉ះពាល់អវិជ្ជមាននៃគម្រោងនិងវិធានការដែលត្រូវដាក់ឲ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន
- បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងហេតុប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លី និងវែងសម្រាប់គម្រោង។

ម្ចាស់គម្រោងត្រូវលើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាពជាផ្នែកមួយនៃការវាយតំលៃហេតុប៉ះពាល់សុខភាព សម្រាប់បរិស្ថានការងារដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និងប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោងរួមទាំងកត្តាគ្រោះថ្នាក់ដល់រូបសាស្ត្រ-គីមីសាស្ត្រជីវសាស្ត្រ និងវិទ្យុសកម្ម។

---

ធាតុ។ ដូចគ្នាផងដែរ ការរួមចំណែកនៃគម្រោងដល់បម្រែបម្រួលអាកាសធាតុ ដែលវាស់វែងតាមរយៈការវិភាគបរិមាណបញ្ចេញឧស្ម័នកាបូនិក ត្រូវជាផ្នែកនៃការវាយតម្លៃបរិស្ថានដែលត្រូវបានពិពណ៌នាក្នុងគោលការណ៍ណែនាំ។

ម្ចាស់គម្រោងត្រូវកំណត់ និងវាយតំលៃពីគ្រោះហានិភ័យ និងសក្ដានុពលនៃហេតុប៉ះពាល់ទៅលើសុវត្ថិភាពនិងសុខភាពរបស់សហគមន៍ក្នុងដំណាក់កាលរចនាគម្រោង សាងសង់គម្រោងប្រតិបត្តិគម្រោង និងបញ្ចប់គម្រោងព្រមទាំងលើកវិធានការការពារ និងផែនការគ្រប់គ្រងហេតុប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ។

## ផ្នែកទី៤
## ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ

### មាត្រា ៤០._វត្ថុបំណងនៃការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ

ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រជំរុញការអភិវឌ្ឍបៃតងដែលធានាដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹង និងការបញ្ជ្រាបគោល នយោបាយ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចដំណើរការសម្រេចចិត្តទៅលើគម្រោងអភិវឌ្ឍន៍នានា។

គោលបំណងនៃការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ សំដៅះ

- ផ្ដល់ឱកាសដល់សកម្មភាពអភិវឌ្ឍន៍ធានាបានការអភិវឌ្ឍប្រកបដោយចរិភាព។
- ជំរុញការពិចារណាលើជម្រើសដ៏ទូលំទូលាយដែលការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងមិនអាចវាយតំលៃ និងវិភាគបាន។
- ជំរុញការវិភាគហេតុប៉ះពាល់ទ្រង់ទ្រាយធំរួមទាំងហេតុប៉ះពាល់ឆ្លងដែនដែលពាក់ព័ន្ធនឹងក្ដីកង្វល់ថ្នាក់ជាតិក្នុងតំបន់ និងនៅលើសកលលោក។
- ជួយដល់ការអនុវត្តផែនការបរិស្ថានជាតិផែនការសកម្មភាពបរិស្ថានជាតិ ជំរុញការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី និងកសាងសមត្ថភាពវាយតំលៃបរិស្ថាន។

### មាត្រា ៤១._វិសាលភាពនៃការអនុវត្ត

ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងត្រូវធ្វើការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រតាមវិស័យទៅលើគោលនយោបាយផែនការយុទ្ធសាស្ត្រ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល។

ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រសំដៅលើវិស័យអភិវឌ្ឍន៍សំខាន់ៗដូចជា ថាមពល ដឹកជញ្ជូន ឧស្សាហកម្មទាញយក (រ៉ែ ធនធានទឹក រុក្ខាប្រមាញ់) ទេសចរណ៍ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យពាក់ព័ន្ធផ្សេងទៀត។

ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងត្រូវទទួលខុសត្រូវពិនិត្យការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ និងត្រូវផ្ដល់មតិយោបល់ដល់ទីភ្នាក់ងារពាក់ព័ន្ធ ដោយតម្រូវឲ្យមានការចូលរួមជាសាធារណៈ។

ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវជំរុញដល់ការអភិវឌ្ឍបៃតងនិងការអភិវឌ្ឍប្រកបដោយចិរភាព ទាំងបរិស្ថាន និងសង្គម តាមរយៈការព្យាករណ៍ និងកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានចាប់ពីដំណាក់កាលរចនាគម្រោងធ្វើផែនការនិងកំណត់ពីជម្រើសគុណភាពបរិស្ថានការប្រើប្រាស់ធនធានធម្មជាតិដោយសន្សំសំចៃនិងទទួលបានទិន្នផលខ្ពស់ព្រមទាំង

ធានាដល់ការអនុវត្តគោលនយោបាយ និងផែនការឲ្យមានស្មេរភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ និងកិច្ចការពារបរិស្ថាននិងសង្គម។

ការរួមបញ្ចូលនូវការវាយតំលៃហេតុប៉ះពាល់បរិស្ថានសម្រាប់កម្រិតគម្រោង និងការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រសម្រាប់កម្រិតគោលនយោបាយ គឺសំដៅដល់ការអភិវឌ្ឍបៃតង ជាពិសេសការដោះស្រាយបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមនៃការរៀបចំផែនការ។ [20] ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងត្រូវរៀបចំឲ្យប្រើប្រាស់ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីវាយតំលៃទំនាក់ទំនងរវាងបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌នៃផែនការតាមវិស័យ។ ។

ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រមានតួនាទីសំខាន់ក្នុងការកំណត់វត្ថុបំណងនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពលើវិស័យជាក់លាក់ ដោយរៀបចំផែនទីតំបន់ងាយរងគ្រោះ វាយតម្លៃពីសកម្មភាពស្នើសុំ និងវិធានការស្នើឡើង សម្រាប់កំណត់ និងវិភាគពីវិធានការជាក់លាក់។

## ផ្នែកទី៥
## ហេតុប៉ះពាល់បរិស្ថានឆ្លងដែន

### មាត្រា ៤២._លក្ខណវិនិច្ឆ័យ និងក្របខ័ណ្ឌត្រួតពិនិត្យចំពោះការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន

គម្រោងដែលអាចមានហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

ក្រសួងបរិស្ថាន ត្រូវបង្កើតគោលការណ៍ណែនាំស្តីពីលក្ខណវិនិច្ឆ័យកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងឈានទៅដល់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

### មាត្រា ៤៣._បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ

នៅពេលគម្រោងចាប់ផ្តើមឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ក្រសួងបរិស្ថានត្រូវបញ្ជូនរបាយការណ៍ពិនិត្យជ្រើសរើសគម្រោង ដល់ប្រទេសទាំងឡាយដែលទទួលរងហេតុប៉ះពាល់ ដោយជូនដំណឹងប្រទេសទាំងនោះអំពីគម្រោងអភិវឌ្ឍន៍ស្នើសុំ។ ក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការពិភាក្សាជាមួយបណ្តាប្រទេសទាំងនោះ អំពីនីតិវិធីនិងពេលវេលា ដើម្បីផ្តល់មតិយោបល់អំពីគម្រោងស្នើសុំ ។

ប្រទេសកម្ពុជាត្រូវផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ និងសាធារណជនឲ្យចូលរួមក្នុងនីតិវិធីវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ទាក់ទងនឹងសកម្មភាពស្នើឡើង ហើយត្រូវធានាផ្តល់ឱកាសដល់សាធារណជននៃប្រទេសដែលអាចទទួលរងហេតុប៉ះពាល់ទាំងនោះ ដូចគ្នានឹងសាធារណជននៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសស្នើគម្រោង។

[20] ចំណុចទាំងនេះពាក់ព័ន្ធនឹងគោលការណ៍ណែនាំ។

នៅពេលក្រសួងបរិស្ថានទទួលបានរបាយការណ៍ពិនិត្យជ្រើសរើសសម្រាប់គម្រោងក្នុងប្រទេសកម្ពុជាដែលមានសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានដល់ប្រទេសមួយទៀត ក្រសួងបរិស្ថានត្រូវជូនដំណឹងដល់អាជ្ញាធរនៃប្រទេសនោះ ដើម្បីប្រមូល និងប្រៀបធៀបការឆ្លើយតបពីអាជ្ញាធរ/ទីភ្នាក់ងារពាក់ព័ន្ធ ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងឲ្យដាក់ការឆ្លើយតបជាផ្លូវការមកក្រសួងបរិស្ថានកម្ពុជា (ប្រទេសស្នើគម្រោង)។ ករណីពុំបានទទួលការឆ្លើយតបក្នុងរយៈពេលជាកំណត់នេះនោះទេ កម្ពុជាសន្មត់ថា ប្រទេសនោះមិនចង់ចូលរួមក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនតទៅទៀតទេ។

នៅពេលក្រសួងបរិស្ថានទទួលរបាយការណ៍ជ្រើសរើសគម្រោង (ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន) ពីប្រទេសមួយសម្រាប់គម្រោងមួយដែលមានហេតុប៉ះពាល់បរិស្ថានជាក់លាក់មកលើប្រទេសកម្ពុជាភាគីកម្ពុជាត្រូវបើកកិច្ចពិភាក្សាភ្លាមៗជាមួយនឹងប្រទេសនោះស្តីពីនីតិវិធី និងពេលវេលាសម្រាប់ការផ្តល់មតិយោបល់អំពីគម្រោងស្នើឡើងនោះ។

អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសស្នើគម្រោងអនុញ្ញាតឲ្យភាគីកម្ពុជាប្រមូល និងប្រៀបធៀបការឆ្លើយតបពីអាជ្ញាធរ/ស្ថាប័ន/ភាគីពាក់ព័ន្ធនៃប្រទេសទទួលរងហេតុប៉ះពាល់ ហើយត្រូវដាក់ការឆ្លើយតបផ្លូវការទៅនឹងសេចក្តីជូនដំណឹងទៅអាជ្ញាធរជាកំណត់នៃប្រទេសស្នើគម្រោងដើមនោះនៅក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃបន្ទាប់ពីទទួលសេចក្តីជូនដំណឹង។ ករណីការឆ្លើយតបមិនបានទទួលក្នុងរយៈពេលជាកំណត់នោះ ប្រទេសស្នើគម្រោងអាចសន្មត់ថា កម្ពុជាមិនចង់ចូលរួមក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនតទៅទៀតទេ។

មតិយោបល់ដែលទទួលបានពីប្រទេសមួយផ្សេងទៀតស្តីពីរបាយការណ៍ជ្រើសរើសគម្រោង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវពិចារណាដោយក្រសួងបរិស្ថាន។ តំណាងនៃប្រទេសដទៃទៀតដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង មានសិទ្ធិមានវត្តមានក្នុងបទបង្ហាញផ្លូវការ និងសវនាការសាធារណៈស្តីពីគម្រោងនៅកម្ពុជា ហើយនឹងទទួលបានឱកាសសម្តែងមតិយោបល់របស់ខ្លួន នៅចំពោះមុខសាធារណជនទូទៅ។

សោហ៊ុយចំណាយរបស់រដ្ឋាភិបាលកម្ពុជា ចំពោះការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង។

## មាត្រា ៩៤._វិធានការកាត់បន្ថយហេតុប៉ះពាល់នៃគម្រោង និងផែនការគ្រប់គ្រងបរិស្ថាន

ម្ចាស់គម្រោងត្រូវលើកវិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីលុបបំបាត់ បន្ធូរបន្ថយ ឬកាត់បន្ថយហេតុប៉ះពាល់នៃគម្រោងស្នើសុំ។ វិធានការទាំងនេះត្រូវពិនិត្យ និងផ្តល់មតិយោបល់ដោយសាធារណជននៅក្នុងប្រទេសកម្ពុជាដែលអាចទទួលរងហេតុប៉ះពាល់ អនុលោមតាមនីតិវិធី និងពេលវេលាដែលបានព្រមព្រៀងគ្នា។

ម្ចាស់គម្រោងត្រូវទទួលយកមតិយោបល់ដែលទទួលបានពីភាគីទាំងអស់ដែលទទួលរងហេតុប៉ះពាល់ ហើយរៀបចំផែនការគ្រប់គ្រងបរិស្ថានសមស្រប ដើម្បីគ្រប់គ្រងលើហេតុប៉ះពាល់ឆ្លងដែន។ ថ្លៃចំណាយនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននិងសង្គម ក្នុងផែនការគ្រប់គ្រងបរិស្ថាន ត្រូវចាត់ទុកជាផ្នែកនៃថ្លៃចំណាយគម្រោង ហើយត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោងដែលជាផ្នែកនៃថ្លៃចំណាយអភិវឌ្ឍន៍ ឬប្រតិបត្តិការ។

ក្នុងករណីមានគ្រោះថ្នាក់ ឬការខូចខាតចំពោះអ្នកដែលទទួលរងហេតុប៉ះពាល់ឆ្លងដែន ម្ចាស់គម្រោងត្រូវទទួលខុសត្រូវលើសំណងការខូចខាត ទាំងប្រជាជនកម្ពុជា និងប្រជាជននៃប្រទេសដែលទទួលរងហេតុប៉ះពាល់ដោយសារគម្រោង។ ថ្លៃគ្រោះថ្នាក់ និងថ្លៃនៃការខូចខាតជាទំនួលទទួលខុសត្រូវរបស់ម្ចាស់គម្រោង។

### មាត្រា ៤៥._ ការពិនិត្យតាមដានគម្រោង

ប្រទេសពាក់ព័ន្ធត្រូវរួមគ្នាកំណត់វិធីសាស្រ្តអង្កេតតាមដាន ឃ្លាំមើលសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដែលអាចកើតមាននៅក្នុងដំណាក់កាលរចនាគម្រោងការសាងសង់ ការប្រតិបត្តិនិងការបញ្ចប់ការងារទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ស្នើសុំនិងផែនការគ្រប់គ្រងបរិស្ថាន។

ម្ចាស់គម្រោងនៃប្រទេសស្នើសុំគម្រោងត្រូវដាក់របាយការណ៍អង្កេតតាមដានបរិស្ថានជារៀងរាល់ឆ្នាំ និងត្រូវធ្វើសវនកម្មដោយក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានត្រូវផ្ញើសំណៅនៃរបាយការណ៍អង្កេតតាមដានបរិស្ថានជូនអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលទទួលរងហេតុប៉ះពាល់។

លទ្ធផលនៃការអង្កេតតាមដានគម្រោងត្រូវតែមានគោលដៅក្នុងការធានាឱ្យបាននូវការអនុលោមតាមល័ក្ខខ័ណ្ឌនានាដែលបានដាក់ចេញ នៅក្នុងលិខិតអនុញ្ញាតឬលិខិតឯកភាពលើគម្រោង និងនៅក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងនោះក៏ដូចជានៅក្នុង ប្រសិទ្ធភាពនៃវិធានការកាត់បន្ថយ[ការប៉ះពាល់]ផ្សេងៗ នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសដែលអាចទទួលរងហេតុប៉ះពាល់។

ថ្លៃចំណាយលើការអង្កេតតាមដានគម្រោងត្រូវទូទាត់ដោយម្ចាស់គម្រោងទាំងនៅក្នុងប្រទេសស្នើសុំគម្រោង និងប្រទេសដទៃទៀត ដែលត្រូវបានវាយតំលៃថាជាប្រទេសទទួលរងហេតុប៉ះពាល់ដោយសារគម្រោង។

## ជំពូកទី ៩
## មូលនិធិបរិស្ថាន

### មាត្រា ៤៦._កាតព្វកិច្ចបង់មូលនិធិសម្រាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

ម្ចាស់គម្រោងត្រូវទទួលរ៉ាប់រងបង់រាល់ការចំណាយទាំងអស់ក្នុងការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងថ្លៃចំណាយសម្រាប់ការពិនិត្យលើរបាយការណ៍ទាំងនេះរបស់ក្រសួងបរិស្ថាន រួមទាំងគណៈកម្មការត្រួតពិនិត្យជំនាញ។

ម្ចាស់គម្រោងត្រូវទទួលខុសត្រូវបង់ថ្លៃចំណាយលើកិច្ចដំណើរការចូលរួមជាសាធារណៈ ផែនការគ្រប់គ្រងបរិស្ថាន និងថ្លៃចំណាយលើការអនុវត្ត និងការអង្កេតតាមដានលើវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម។

ម្ចាស់គម្រោងត្រូវបង់វិភាគទាន១% នៃថ្លៃគម្រោងចូលទៅក្នុងមូលនិធិបរិស្ថាននិងសង្គមរបស់ក្រសួងបរិស្ថាន មុននឹងចាប់ផ្តើមគម្រោង។

**មាត្រា ៤៧._ថ្លៃ និងបន្ទុកសេវា**

នៅពេលចេញវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថានមានភារកិច្ចប្រមូលថ្លៃ និងបន្ទុកសេវា ដូចមានចែងនៅក្នុងប្រកាសរួមរវាងក្រសួងបរិស្ថាននិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីការបង់ថ្លៃសេវាការងារ សម្រាប់ការពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ថ្លៃចំណាយ៥០ភាគរយត្រូវបង់ចូលថវិកាជាតិ និងថ្លៃចំណាយ៥០ភាគរយទៀតសម្រាប់ក្រសួងបរិស្ថានប្រើប្រាស់ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងរក្សាធនធានអេកូឡូស៊ី និងអភិរក្សបរិស្ថាន។

**មាត្រា ៤៨._មូលនិធិបរិស្ថាន**

មូលនិធិទាយជ្ជទានបរិស្ថានដែលបង្កើតឡើងក្រោមមាត្រា១៩ នៃច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវរាប់បញ្ចូលវិភាគទានពីម្ចាស់គម្រោង ដូចដែលតម្រូវ និងអនុលោមតាមគោលការណ៍ណែនាំ ដែលចេញដោយក្រសួងបរិស្ថាន។

មូលនិធិបរិស្ថាន និងសង្គមត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថាន ដើម្បីបន្តជំរុញនិងផ្ដល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍបរិស្ថាន និងសង្គមនៅតំបន់គម្រោងដែលតាំងនៅ។

ម្ចាស់គម្រោងត្រូវបង់វិភាគទានទៅក្នុងមូលនិធិទាំងនេះ អនុលោមតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថានស្ដីពីការរួមវិភាគទានដាច់ខាតទៅក្នុងមូលនិធិបរិស្ថាន។ មូលនិធិនេះត្រូវប្រើប្រាស់និងចាត់ចែងតាមនីតិវិធីដោយក្រសួងបរិស្ថាន ដើម្បីអភិរក្សធនធានអេកូឡូស៊ី និងអភិរក្សបរិស្ថាន។

**មាត្រា ៤៩._រង្វាន់**

ក្រសួងបរិស្ថាន មន្ទីរបរិស្ថានរាជធានី ខេត្ត ឬក្រុង និងទីភ្នាក់ងារទទួលខុសត្រូវ បរិស្ថាន និងរដ្ឋបាលមូលដ្ឋាន មានសិទ្ធិធ្វើសំណើសុំរង្វាន់ ឬវិញ្ញាបនបត្ររង្វាន់ ឬទម្រង់ពាក្យទទួលស្គាល់ដទៃទៀត ចំពោះការសម្រេចបាននូវកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា ឲ្យទៅបុគ្គល អង្គភាព ក្រុមហ៊ុន ឬអង្គការណាមួយដែលមានស្នាដៃឆ្នើមក្នុងសកម្មភាពវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

## ជំពូកទី ១០
## មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៥០._ការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌**

មន្ត្រីអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានអនុញ្ញាតឲ្យដើរតួជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសនានាពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់ប

វិស្ថាន និងកសាងសំណុំរឿងដើម្បីដាក់ជូនតុលាការមានសមត្ថកិច្ច និងត្រូវអនុវត្តការងារដូចខាងក្រោម៖

-ការស្រាវជ្រាវ ពិនិត្យតាមដាន បង្ការ និងបង្ក្រាបបទល្មើសនានា ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនបានរៀបចំរបាយការណ៍នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន មិនបានអនុវត្តវិធានការដែលបានចែងក្នុងកិច្ចព្រមព្រៀងការពារបរិស្ថាន និងបញ្ញត្តិដទៃទៀតពាក់ព័ន្ធនឹងវាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺជាសិទ្ធិអំណាចរបស់ក្រសួងបរិស្ថាន។

- មុនពេលចាប់ផ្តើមបេសកកម្មស្រាវជ្រាវ ពិនិត្យតាមដាន បង្ការ និងបង្ក្រាបបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីនគរបាលយុត្តិធម៌នៃអគ្គនាយដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវស្លៀកពាក់ឯកសណ្ឋាន មានប័ណ្ណសម្គាល់ខ្លួនឋានន្តរសក្តិនិងលិខិតបេសកកម្មមួយច្បាប់។

មន្ត្រីអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើសម្បថមុខសាលាឧទ្ធរណ៍ដើម្បីទទួលបានការទទួលស្គាល់ក្នុងការបំពេញការងារជាមន្ត្រីនគរបាលយុត្តិធម៌។បែបបទ និងនីតិវិធីនៃការស្បថត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលត្រូវបានទទួលស្គាល់ជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវរៀបចំ និងចុះហត្ថលេខាលើកំណត់ត្រាបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

### មាត្រា ៥១._មន្ត្រីនគរបាលយុត្តិធម៌នៃអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន

មន្ត្រីនគរបាលយុត្តិធម៌នៃអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានដែលមាននីតិសម្បទាអាចឃាត់ខ្លួនជនល្មើសទាក់ទងនឹងបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន។ រយៈពេល និងនីតិវិធីនៃការឃាត់ខ្លួនត្រូវអនុលោមតាមមាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

# ជំពូកទី ១១
# បទល្មើស និងទោសប្បញ្ញត្តិ

## ផ្នែកទី១៖គោលការណ៍ទូទៅ

### មាត្រា ៥២._បទល្មើស និងអំពើរំលោភច្បាប់វាយតំលៃហេតុប៉ះពាល់បរិស្ថាន

បទល្មើស ក្នុងច្បាប់នេះ រាប់បញ្ចូលគ្រប់សកម្មភាពល្មើស ការមិនគោរព ការរំលោភបំពានច្បាប់ទាំងឡាយ នៃរូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំឲ្យកើតមានហេតុប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌។

### មាត្រា ៥៣._ទោសទណ្ឌនៃបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ទោសទណ្ឌចំពោះបទល្មើសនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានមាន ការផ្តន្ទាទោសដាក់ពន្ធនាគារ ទោសពិន័យជាប្រាក់ ពិន័យអន្តរកាល ព្រមាន រឹបអូសវត្ថុតាង ជួសជុល ស្តារការ

ខូចខាត កែតម្រូវ បញ្ឈប់ ផ្អាកបណ្តោះអាសន្នឬព្យួរ លុបលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រឯកភាពលើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដកអាជ្ញាប័ណ្ណវិនិយោគឬលិខិតអនុញ្ញាតអាជីវកម្ម ឬផលិតកម្ម លុបកិច្ចសន្យា។

## មាត្រា ៥៤._សមត្ថកិច្ចដែលត្រូវដាក់ទោសទណ្ឌ

- **តុលាការ** (ទោសដាក់ពន្ធនាគារ ពិន័យជាប្រាក់ សំណងការខូចខាត ជួសជុល ស្តាការខូចខាតតាមករណីនិមួយៗ)
- **ក្រសួងបរិស្ថាន** (ជួសជុល ស្តាការខូចខាត ការផ្អាកបណ្តោះអាសន្ន លុបលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រឯកភាពលើការវាយតំលៃហេតុប៉ពាល់បរិស្ថាន លុបកិច្ចសន្យា)
- **អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានខេត្តរាជធានី**(ព្រមាន កែតម្រូវ រឹបអូសវត្ថុតាង)

## មាត្រា ៥៥._ សិទ្ធិវាយការណ៍អំពីការបំពាន21

រូបវន្តបុគ្គល ឬនីតិបុគ្គលណាក៏ដោយមានកាតព្វកិច្ចត្រូវវាយការណ៍អំពីបទល្មើសលើការរំលោភបំពានលើច្បាប់នេះ មកអាជ្ញាធរមូលដ្ឋាន ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/រាជធានី បន្ទាប់ពីបានទទួលសេចក្តីវាយការណ៍ អាជ្ញាធរគ្រប់ថ្នាក់ត្រូវវាយការណ៍បន្តជូនក្រសួងបរិស្ថាន អំពីសកម្មភាពដែលបំពានលើច្បាប់នេះ និងគោលការណ៍ណែនាំ និងដែលបង្កហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរចំពោះបរិស្ថាន។ ក្រោយពីបានទទួលសេចក្តីវាយការណ៍ ក្រសួងបរិស្ថាន/អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើការអង្កេត និងចាត់ចែងករណី អនុលោមតាមច្បាប់ និងគោលការណ៍ណែនាំ។

## មាត្រា ៥៦._[22] ការកសាងសំណុំរឿងបរិស្ថាន

ការកសាងសំណុំរឿង[23]ពាក់ព័ន្ធបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

ទម្រង់និងបែបបទនៃការធ្វើកំណត់ហេតុបទល្មើសនៃការវាយតំលៃហេតុប៉ះពាល់បិរស្ថាន ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌។

[21]មាត្រានេះយកចេញពី មាត្រា ៥ នៃបទប្បញ្ញត្តិ PRC EIA ឆ្នាំ២០០៩

[22]សូមមើលសេចក្តីព្រាង ក្រសួងបរិស្ថាន មាត្រា ៤២

[23]ទី១ ការស៊ើបអង្កេត ស្រាវជ្រាវ បទល្មើស ទី២ ការសុំគោលការណ៍ពីព្រះរាជអាជ្ញាក្នុងការខាត់ខ្លួន ទី ៣ ស្នើសុំឲ្យព្រះរាជអាជ្ញាដឹកនាំផ្ទាល់ការចែកឆេ ទី៤ ការឆែកឆេ ទី៥ ឃាត់ ទី៦ ការដកហូតវត្ថុតាង ទី៧ ការទទួលស្គាល់វត្ថុតាង ទី៨ កំណត់ហេតុយកចម្លើយសាក្សី អ្នកពាក់ព័ន្ធ ជនល្មើស ទី៩ របាយការណ៍ព្រឹត្តិហេតុ ទី១០ របាយការណ៍សំយោគ។

**មាត្រា ៥៧._ប្រភេទ នៃបទល្មើស**

បទល្មើសទាក់ទងនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថានមាន

- បទល្មើសរដ្ឋបាល
- បទល្មើសព្រហ្មទណ្ឌ

## ផ្នែកទី២៖ បទល្មើសរដ្ឋបាល

**មាត្រា ៥៨._អាជ្ញាយុកាល នៃ បណ្ដឹង**

អាជ្ញាយុកាលចំពោះបណ្ដឹងនៃបទល្មើសមានៈ

- បណ្ដឹងរដ្ឋបាលមានរយៈពេល ០១ (មួយ) ឆ្នាំ
- បណ្ដឹងបទមជ្ឈឹមមានរយៈពេល ០៥ (ប្រាំ) ឆ្នាំ
- បណ្ដឹងចំពោះបទឧក្រិដ្ឋមានរយៈពេល១៥ (ដប់ប្រាំ) ឆ្នាំ។

អាជ្ញាយុកាលនៃបទល្មើសគឺអនុវត្តគិតចាប់ពីថ្ងៃដែលអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ចបានប្ដឹងឬទទួលបណ្ដឹងពីបទល្មើស។

**មាត្រា ៥៩._ទណ្ឌកម្មទាក់ទងនឹងការធ្វើអធិការកិច្ច**

បុគ្គល ឬក្រុមហ៊ុនដែលមិនសហការឬ មិនអនុញ្ញាត ឬមានចេតនាគេចវេសក្នុងការឲ្យមន្ត្រីអធិការកិច្ច នៃអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានជួបជាមួយប្រធានក្រុមប្រឹក្សាភិបាល និងអ្នករដ្ឋបាល ដើម្បីធ្វើការវាយតំលៃលើការអនុវត្ត ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ៧ មាត្រា១២នៃច្បាប់នេះត្រូវទទួលការព្រមានពីអគ្គនាយកដ្ឋាននៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថាន នៃក្រសួងបរិស្ថាន ។ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀលដល់ ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល។

**មាត្រា ៦០._បទល្មើសនិងទណ្ឌទាក់ទងនឹងការធ្វើរបាយការណ៍**

បុគ្គលឬក្រុមហ៊ុនឬស្ថាប័ន ដែលប្រព្រឹត្តល្មើសនឹងល័ក្ខខ័ណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថាន ត្រូវទទួលការព្រមាន។ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលដល់១៥.០០០.០០០(ដប់ប្រាំលាន)រៀល។ ក្នុងករណីដែលគម្រោងឬសកម្មភាពខុសច្បាប់នោះនៅតែបន្តហើយធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់បិរិស្ថាន និងសង្គម នោះម្ចាស់ក្រុមហ៊ុននឹងទទួលទណ្ឌកម្មព្រហ្មតាមបញ្ញតិច្បាប់ហើយវត្ថុតាងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

**មាត្រា ៦១._ការបំពានការមិនបំពេញកាតព្វកិច្ច ឬ តួនាទីរបស់មន្ត្រីនគរបាលយុត្តិធមិ**

មន្ត្រីនគរបាលយុត្តិធមិនៃអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានដែល បំពានឬប្រកែកឬមានចេតនាគេចវេសឬមិន បំពេញតួនាទីរបស់ខ្លួនមានចែងក្នុងវាក្យខ័ណ្ឌទី១ទី២ទី៣ មាត្រា ៥០ និងវាក្យខ័ណ្ឌទី៣មាត្រា៨នៃច្បាប់នេះ នឹងត្រូវព្រមានឬព្យួរការងារជាបណ្ដោះ

អាសន្ន ឬបញ្ឈប់ពីមុខតំណែងក្នុងករណីធ្ងន់ធ្ងរ។ ការបញ្ឈប់ពីតំណែងនេះមិនរារាំងក្នុងការដាក់ទោសព្រហ្មទណ្ឌពីតុលាការឡើយ។ មន្ត្រីផ្សេងទៀតដែលបំពាន មិនបំពេញតួនាទីរបស់ខ្លួននឹងត្រូវផ្តន្ទាទោសរដ្ឋបាល។

**មាត្រា ៦២._បទល្មើស ទោសទណ្ឌ**

គ្រប់គម្រោងស្នើសុំ ដែលមិនទាន់ទទួលបាននូវវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា២២នៃច្បាប់នេះនឹងត្រូវទទួលទោសទណ្ឌ និងត្រូវហាមឃាត់មិនឲ្យមានការសាងសង់ឬដំណើរការគម្រោងឡើយ។ ម្ចាស់គម្រោងណាម្នាក់ ដែលល្មើសនឹងល័ក្ខខ័ណ្ឌតម្រូវខាងលើត្រូវទទួលរងទោសទណ្ឌដោយបង់ប្រាក់ពិន័យការផ្អាកគម្រោងភ្លាមៗ និងលទ្ធភាពអាចបាត់បង់នូវការឯកភាពលើគម្រោងពីរាជរដ្ឋាភិបាល។

ក្នុងករណីដែលគម្រោង ការដ្ឋាន បានដំណើរ ហើយធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន និងសង្គមជាអវិជ្ជមាន នោះម្ចាស់គម្រោងនឹងត្រូវជួសជុល ស្តាការខូចខាត ហើយគម្រោងអាចត្រូវបាន ផ្អាកបណ្តោះអាសន្ន លុបលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ លុបកិច្ចសន្យា ការដកហូតអាជ្ញាប័ណ្ណ។

ការចេញបញ្ជាឲ្យបញ្ឈប់ប្រតិបត្តិការ គឺមានការពាក់ព័ន្ធនឹងការពិចារណារបស់ គណៈកម្មាធិការរៀបចំផែនការ និងវិនិយោគ (ឬការិយាល័យនៅតាមរាជធានី ខេត្តរបស់ខ្លួន) ។ចំពោះការដកហូតអាជ្ញាប័ណ្ណប្រតិបត្តិការ គឺមានការពាក់ព័ន្ធនឹងការពិចារណារបស់ គណៈកម្មាធិការអន្តរក្រសួងដោយយោងតាមសំណើរបស់របស់ក្រសួងបរិស្ថាន/អគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើការស្នើសុំដកហូតអាជ្ញាប័ណ្ណវិនិយោគរបស់ម្ចាស់គម្រោង។

នៅពេលគម្រោងត្រូវបានហាមឃាត់មិនឲ្យបន្តដំណើរការ ម្ចាស់គម្រោងត្រូវសង ការខូចខាតនានាដែលបានបង្កឡើងធ្វើឲ្យខូចខាតដល់បរិស្ថាន។

**មាត្រា ៦៣._វិធានការកែតម្រូវ និងទោសទណ្ឌ**

វិធានការកែតម្រូវ និងទោសទណ្ឌដែលត្រូវកំណត់សម្រាប់បទល្មើស ដែលមានចែង ក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឬច្បាប់ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ត្រូវកំណត់តាមករណីនីមួយៗដោយក្រសួងបរិស្ថាន។ វិធានការត្រូវអាស្រ័យលើភាពធ្ងន់ធ្ងរនៃអំពើល្មើស ដែលកើតឡើងដោយសារគម្រោង ឬប្រតិបត្តិការ ឬអ្នករដ្ឋបាល ឬម្ចាស់ភាគហ៊ុន របស់គម្រោង ឬប្រតិបត្តិការនោះមានកំហុសពាក់ព័ន្ធនឹងបទល្មើស ដំណាក់កាលដែលរកឃើញបទល្មើស និងវិធានការសមស្របដើម្បីកែតម្រូវ ឬបញ្ចប់បទល្មើស នោះក្រសួងបរិស្ថានត្រូវ។

- ចេញសេចក្តីព្រមានជាលាយលក្ខណ៍អក្សរ។
- ចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយប្រធានក្រុមប្រឹក្សាភិបាល ដែលចែងអំពីកម្មវិធីនៃវិធានការកែតម្រូវ។
- ចេញបទបញ្ជាត្រួតពិនិត្យជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ឈប់ និងបញ្ចប់បទល្មើសបែបនេះ ហើយចាត់វិធានការកែតម្រូវ។

- ដាក់កំណត់ល័ក្ខខ័ណ្ឌតម្រូវ និងល័ក្ខខ័ណ្ឌបរិស្ថានលើគម្រោង ឬប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីកែលម្អការគ្រប់គ្រងបរិស្ថានរបស់ខ្លួន។

- ដកហូតវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគម្រោង ឬប្រតិបត្តិការ និងចេញបទបញ្ជាឲ្យបញ្ឈប់ប្រតិបត្តិការ រហូតទាល់តែគម្រោង ឬប្រតិបត្តិការនោះទទួលបានការឯកភាពយល់ព្រម សម្រាប់វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានថ្មីមួយ។

វិធានការ និងទោសទណ្ឌដែលមានចែងនៅក្នុងមាត្រានេះ មិនរារាំងដល់ការអនុវត្តសំណងរដ្ឋប្បវេណី ឬទណ្ឌកម្មព្រហ្មទណ្ឌដទៃទៀត ដូចមានចែងនៅក្នុងច្បាប់នេះនឹងច្បាប់ដទៃទៀតជាធរមានឡើយ។

ទឹកប្រាក់ដែលបានមកពីការកំណត់សំណងការខូចខាត ឬប្រាក់ពិន័យដែលបានកំណត់ដោយអនុលោមតាមជំពូកនេះ ឬប្រាក់ដែលទទួលបានដោយអនុលោមតាមមាត្រានេះ ត្រូវបានបែងចែកៈ

- ទឹកប្រាក់ដំបូងត្រូវបង់ ឲ្យទៅជនរងគ្រោះនៃអំពើរំលោភបំពាន។

- ទឹកប្រាក់ទីពីរត្រូវបង់ថ្លៃចំណាយផ្ទាល់របស់ក្រសួងបរិស្ថាន ក្នុងការស៊ើបអង្កេត ការពិនិត្យតាមដាន និងដំណើរការបណ្តឹង និង ទឹកប្រាក់នៅសល់ ត្រូវទូទាត់ឲ្យទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ប្រសិនបើម្ចាស់គម្រោង មិនបានកែលំម្អវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដើម្បីបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃផែនការគ្រប់គ្រងបរិស្ថាន ក្នុងរយៈពេលកំណត់ដែលបានព្រមព្រៀងទេនោះ គម្រោងនឹងត្រូវបានបិទជាបណ្តោះអាសន្ន រហូតទាល់តែល័ក្ខខ័ណ្ឌនានាត្រូវបានបំពេញ ហើយម្ចាស់គម្រោងទទួលរងនូវការពិន័យស្មើនឹងការខូចខាតលើសង្គម និងបរិស្ថាន និងថ្លៃចំណាយដែលបង្កឡើងដោយគម្រោង និងបានទទួលរងដោយភាគីពាក់ព័ន្ធ។

- ដាក់ពិន័យលើគម្រោង ឬប្រតិបត្តិការ ឬលើអ្នកគ្រប់គ្រងគម្រោង ក្នុងចំនួនទឹកប្រាក់ពី ១.០០០.០០០(មួយលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងមួយថ្ងៃសម្រាប់ថ្ងៃនីមួយៗដែលបទល្មើសបន្តកើតឡើង។ គោលការណ៍នៃការដាក់ពិន័យនេះអនុវត្តចំពោះបទល្មើសដែលមានទំហំ លក្ខណៈ ការខូចខាតប្រហាក់ប្រហែលគ្នា ចំពោះ គ្រប់គម្រោង និងការដ្ឋានសាងសង់។

## មាត្រា ៦៤._ បទល្មើសប្រព្រឹត្តដោយអ្នកជំនាញនិងក្រុមហ៊ុនទីប្រឹក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ក្រុមហ៊ុនទីប្រក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬអ្នកវាយតំលៃហេតុប៉ះពាល់បរិស្ថានដែលបានចុះបញ្ជីស្របច្បាប់ ឬទទួលស្គាល់ពីក្រសួងបរិស្ថានតែបានបន្លំ ក្លែងទិន្នន័យឬយកទិន្នន័យអ្នកដ៏ទៃ ឬរំលោភបំពាននឹងបញ្ញតិនៃច្បាប់នេះ នឹងត្រូវទទួលទោសពិន័យជាប្រាក់ពី (១០.០០០.០០០)(ដប់លាន) រៀលដល់ ២០.០០០.០០០ ម្ភៃលានរៀល ក្នុងករណីមានកំហុស

ធ្ងន់ធ្ងរត្រូវលុបឈ្មោះពីបញ្ជីអ្នកជំនាញធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬមិនឲ្យប្រកបវិជ្ជាជីវៈជារៀងរហូត។

# ផ្នែកទី៣៖ បទល្មើសព្រហ្មទណ្ឌ

**មាត្រា ៦៥._ លក្ខខ័ណ្ឌត្រូវដាក់ទណ្ឌកម្មព្រហ្មទណ្ឌ និងការផាកពិន័យ និងអនុទោស**

**បុគ្គលដែលត្រូវទទួលខុសត្រូវចំពោះអំពើល្មើស រួមមាន៖**

បុគ្គលដែលមានសិទ្ធិសម្រេច និងបុគ្គលទទួលបន្ទុកសកម្មការសាងសង់ វិនិយោគ និងសកម្មភាពពាណិជ្ជកម្មរបស់រូបវន្តបុគ្គល និង នីតិបុគ្គល។

អ្នកផ្ដើមគំនិត អ្នកសមគំនិត អ្នកបិទបាំង អ្នកធ្វើអន្តរាគមន៍ឲ្យប្រព្រឹត្តបទល្មើស អ្នកទទួលផលពីអំពើល្មើស។

ជនដែលអនុវត្តការងារ តាមបញ្ជាគណៈគ្រប់គ្រង ថ្នាក់ដឹកនាំ អ្នកបច្ចេកទេស អ្នកវិជ្ជាជីវៈ និងពលករ ដែលបានដឹងអំពីបទល្មើស ហើយនៅតែប្រព្រឹត្តដើម្បី ទទួលកម្រៃខុសប្រក្រតី។

**មាត្រា ៦៦._បទល្មើស និង ទណ្ឌកម្មនៃការរារាំងមន្ត្រីអធិការកិច្ច**

ជនណាដែលមិនព្រមសហការ ឬ រាំងមន្ត្រីអធិការកិច្ចនៃអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានចូលទៅក្នុងបរិវេណ នៃទីតាំងគម្រោងដើម្បីធ្វើអធិការកិច្ចដូចមានចែងក្នុងវាក្យខ័ណ្ឌទី៦មាត្រា១២ នៃច្បាប់នេះត្រូវពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលដល់ ១៥.០០០.០០០(ដប់ប្រាំលាន) រៀល ក្នុងករណីដែលធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំដល់ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលដល់ ១៥.០០០.០០០(ដប់ប្រាំលាន) រៀល ។ ក្នុងករណីធ្ងន់ធ្ងរប៉ះពាល់ដល់អាយុជីវិតមនុស្សត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៦៨ នៃច្បាប់នេះ។

**មាត្រា ៦៧._បទល្មើសប្រព្រឹត្តដោយអ្នកជំនាញនិងក្រុមហ៊ុនទីប្រឹក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន។**

រូបវន្តបុគ្គលឬ នីតិបុគ្គល មិនមានលក្ខណៈសម្បត្តិ លក្ខណៈវិនិច្ឆ័យនិងទទួលស្គាល់ស្របច្បាប់ ជាក្រុមហ៊ុនទីប្រក្សាឬអ្នកជំនាញការវាយតំលៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់នេះ ហើយបានប្រព្រឹត្តល្មើសធ្ងន់ធ្ងរ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែដល់ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ដល់ ២០.០០០.០០០ (ដប់ប្រាំលាន) រៀល។

**មាត្រា ៦៨._ការបំពានរបស់មន្ត្រីនគរបាលយុត្តិធមិ**

ក្នុងករណីណាក៏ដោយ មន្ត្រីនរគបាលយុត្តិធមិមិនអាចតម្កល់រឿងព្រហ្មទណ្ឌទាក់នឹងបទល្មើសការវាយតំលៃហេតុះប៉ះពាល់បរិស្ថានណាមួយទុកឥតចាត់ការបានទេ។

មន្ត្រីនគរបាលយុត្តិធម៌ដែលរក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនាឬលាក់បំបាំង អាជ្ញាធរតុលាការអំពីអត្ថិភាពនៃកំណត់ហេតុ ឬវត្ថុតាង ត្រូវចាត់ទុកថាមន្ត្រីនគរបាលនោះ បានប្រព្រឹត្តបទល្មើសហើយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ។

## មាត្រា ៦៩._ បទល្មើសបង្ករគ្រោះថ្នាក់ ការបាត់បង់ជីវិតមនុស្ស សត្វ អន្តរាយដល់បរិស្ថាន សង្គម និងទ្រព្យសម្ភារៈ

ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ទៅ១០ (ដប់) ឆ្នាំ ចំពោះរាល់សកម្មភាពគម្រោង ការដ្ឋានសាងសង់ សំណង់ទូទៅ សំណង់ពាណិជ្ជកម្ម ការវិនិយោគ និងគ្រប់សកម្មភាពទោះមានលិខិតអនុញ្ញាតពីអគ្គនាយកដ្ឋានវាយតំលៃ ហេតុប៉ះ ពាល់ បរិស្ថាន ឬគ្មានក្តី ដែលមិនបានអនុវត្តតាមគោលការណ៍នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬរំលោភបំពានច្បាប់ ឬប្រព្រឹត្តអំពើដែលបណ្តាលឲ្យមនុស្សស្លាប់ ពិការអចិន្ត្រៃយ៍ទាំងរាងកាយ និងស្មារតី និងមហន្តរាយដល់ជីវិតសត្វ និងបរិស្ថានធ្ងន់ធ្ងរ ។

ចារី និងសហចារីត្រូវសងសំណងខូចខាតព្យសនកម្មដែលកើតចេញពីអំពើល្មើស និងត្រូវផាកពិន័យជាប្រាក់ពី៥០.០០០.០០០(សែសិបលាន)រៀល ទៅ១០០.០០០.០០០ (មួយរយលាន)រៀលដាក់ចូលក្នុងមូលនិធិវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន។ ក្នុងករណីធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសជាទោសបន្ថែមដល់ អភិបាល អ្នកទទួលខុសត្រូវដទៃទៀត ។

## មាត្រា ៧០._ ការប្រព្រឹត្តល្មើសដោយកងកំលាំងប្រដាប់អាវុធ និង មន្ត្រីរាជការសាធារណៈផ្សេងទៀត

រាល់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ ឬ ពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោតដែលសម្រួល ធ្វើអន្តរាគមន៍ បិទបាំង រារាំង ឬសមគំនិតជាមួយនឹងចារី ដើម្បីប្រព្រឹត្តល្មើសគ្រប់រូបភាពដោយរំលោភលើសិទ្ធិ និងអំណាច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ២ (ពីរ) ឆ្នាំ និងត្រូវបង្គាប់ឲ្យសងសំណង ដែលមានចំនួនសមាមាត្រនឹងការខូចខាតដែលបង្កឡើងព្រមទាំងត្រូវពិន័យជាប្រាក់ពី១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (សែសិបលាន)រៀល។

## មាត្រា ៧១._ នីតិវិធីអនុវត្ត

១. បទល្មើស និងអំពើរំលោភបំពានលើច្បាប់នេះត្រូវអនុវត្តនីតិវិធីដូចតទៅ៖

ក. តាមដានស្រាវជ្រាវ។

ខ. ត្រួតពិនិត្យអធិការកិច្ច។

គ. ការអនុវត្តចំពោះបទល្មើសជាក់ស្តែង និងស៊ើបអង្កេតបឋម។

ច. ការបញ្ជូនរឿងទៅអយ្យការ។

ឆ. កិច្ចការពារក្នុងនាមជាម្ចាស់ករណីម្ចាស់បណ្តឹងក្នុងដំណាក់កាលស៊ើបសួរ។

ជ. កិច្ចការពារសំណុំរឿងក្នុងនាមម្ចាស់បណ្តឹងក្នុងពេលសវនាការ។

ឈ. ការចូលរួមអនុវត្តសាលក្រម សាលដីការ ឬសេចក្តីសម្រេចស្ថាពរ។

**មាត្រា ៧២._ សមត្ថកិច្ចទប់ស្កាត់ បង្ក្រាបបទល្មើសវាយតំលៃហេតុប៉ះពាល់ បរិស្ថាន**

រាល់សកម្មភាពអំពើល្មើស ការរំលោភបំពានប៉ះពាល់នឹងច្បាប់វាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង មន្ត្រីនគរបាលយុត្តិធម៌នៃ ក្រសួងបរិស្ថាន។

**មាត្រា ៧៣._ការអនុវត្តតួនាទីមន្ត្រីនគរបាលយុត្តិធម៌តាមដំណាក់កាលនីតិវិធី**

១. នៅគ្រប់ដំណាក់កាលនៃការអនុវត្តនីតិវិធីបង្ការ បង្ក្រាបបទល្មើស មន្ត្រីនគរបាលយុត្តិធម៌វាយតំលៃហេតុប៉ះពាល់បរិស្ថាន មានតួនាទីជាម្ចាស់បណ្តឹង ម្ចាស់ករណីលើគ្រប់បទល្មើស។

២. ក្រោយបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ ដែល ទទួលបន្ទុកការងារ ដែលមានលិខិតចាត់តាំងត្រូវមានភារៈកិច្ច ការការពារសំណុំរឿង ក្នុងនាមម្ចាស់ករណី និង/ឬម្ចាស់បណ្តឹងដោយការទទួលខុសត្រូវខ្ពស់។

៤. នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកម្ចាស់ករណីនិង/ឬម្ចាស់បណ្តឹងត្រូវមានវត្តមានតាមដាន ចូលការពារសំណុំរឿង បំភ្លឺផ្តល់គ្រប់មធ្យោបាយនានាតាមផ្លូវច្បាប់ និងផ្តល់ភស្តុតាងដើម្បីជាប្រយោជន៍ ក្នុងសំណុំរឿងជាការយកចិត្តទុកដាក់ ការទទួលខុសត្រូវលើនីតិវិធី និងសំណុំរឿងដើម្បីឲ្យការកាត់ក្តីប្រកបដោយយុត្តិធម៌។

៥. **<u>នៅដំណាក់កាលជំនុំជម្រះ សវនាការ៖</u>**

នៅគ្រប់សំណុំរឿងពីករណីបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីនគរបាលយុត្តិធម៌វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបន្ទុកទទួលខុសត្រូវជាម្ចាស់បណ្តឹង និង/ឬម្ចាស់ករណីត្រូវមានវត្តមានថ្លែងហេតុ ធ្វើរបាយការណ៍ ការពារភស្តុតាង អង្គហេតុ អង្គច្បាប់នៃបណ្តឹងលើបទល្មើស ដើម្បីជួយឲ្យការកាត់ក្តីប្រកបដោយយុត្តិធម៌និងបន្ថែមពីនេះមន្ត្រីទទួលបន្ទុកមានសិទ្ធិសំណូមពរ និងទាមទារ តាមផ្លូវច្បាប់ទាក់ទងនឹងរឿងក្តី។

៦. **<u>ការប្តឹងតវ៉ា បណ្តឹងឧបាស្រ័យ៖</u>**

បណ្តឹងតវ៉ា និងសេចក្តីសម្រេចផ្លូវរដ្ឋបាល អ្នកមិនសុខចិត្តអាចប្តឹងទៅអគ្គនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថានតាមឋានានុក្រម។ ក្នុងករណីដែលភាគីមិនសុខចិត្តនិងសេចក្តីសម្រេចរបស់តុលាការភាគីអាចប្តឹង ទៅតុលាការជាន់លើតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា ៧៤._ អំពីសំណង និងការផាកពិន័យ**

១. សំណង និងការផាកពិន័យក្នុងបទល្មើសនៃច្បាប់នេះ គឺជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

២. សំណង និងការផាកពិន័យដែលបានមកពីបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន អនុវត្តតាមសម្រេចនានា សាលក្រម សាលដីកាស្ថាពរ តុលាការត្រូវប្រគល់ភារកិច្ចឲ្យអគ្គនាយកដ្ឋាន វាយតំលៃហេតុប៉ះពាល់បរិស្ថាន ជាអ្នកទាមទារ និង ទទួលចាត់ចែង ។

# ជំពូកទី ១២
# ការអនុវត្តន៍សេចក្តីសម្រេចតុលាការ

**មាត្រា៧៥._ ការអនុវត្តសេចក្តីសម្រេចតុលាការ**

ការអនុវត្តសាលក្រមសាលដីកាស្ថាពរនៃបទល្មើសវាយតំលៃហេតុប៉ះពាល់បរិស្ថាន ជាភារៈកិច្ចរបស់បន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងបរិស្ថានលើកលែងតែទោសជាប់ពន្ធនាគារ។

**មាត្រា៧៦._ការប្រគល់សាលក្រមដល់ក្រសួងមានសមត្ថកិច្ច**

រាល់ទម្រង់សាលក្រម ឬសាលដីកា នៃបទល្មើសវាយតម្លៃហេតុប៉ះពាល់បរិស្ថានតម្រូវចម្លងជូនមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា៧៧._ការចាត់ចែងវត្ថុតាងដែលរឹបអូសបាន**

បន្ទាប់ពីសាលាក្រម ឬសាលដីជាចូលជាស្ថាពរ វត្ថុតាងដែលបានរឹបអូសបានត្រូវចាត់ចែង តាមនីតិវិធីដោយក្រសួងបរិស្ថាន។

# ជំពូកទី ១៣
# អន្តរប្បញ្ញត្តិ

**មាត្រា៧៨ ._ អន្តរប្បញ្ញត្តិ**

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតំលៃហេតុ ប៉ះពាល់បរិស្ថានដែលនៅជាធរមាននៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមស្មារតីនៃច្បាប់នេះ។

# ជំពូកទី ១៥
# អវសានប្បញ្ញត្តិ

**មាត្រា៧៩._ អវសានប្បញ្ញត្តិ**

១. បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

២. ការចូលជាធរមានក្នុងការអនុវត្តច្បាប់នេះនឹងត្រូវអនុវត្តតាមប្រកាសផ្សព្វផ្សាយជាផ្លូវការ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ...........
ក្នុងសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៥។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ...........

**ប្រធានរដ្ឋសភា**

ឧបសម្ព័ន្ធទី ១៖

# វាក្យសព្ទ

**ច្បាប់ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន**
ច្បាប់នេះចែងនិងបញ្ញត្តិអំពីការគ្រប់គ្រងលើកិច្ចដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងព្រះរាជាណាចក្រកម្ពុជា។ រាល់សកម្មភាព ចលនា ការប្រព្រឹត្តទាំងអស់របស់បុគ្គល គ្រួសារ ម្ចាស់ទីតាំង ម្ចាស់កម្មសិទ្ធិ ទោះជារូបវន្តបុគ្គល ជានីតិបុគ្គលឯកជន ឬជានីតិបុគ្គលសាធារណៈ ជាអង្គភាព ជាក្រសួង ជាស្ថាប័នរដ្ឋ ឬជារដ្ឋនិងរដ្ឋក្តី ដែលបានធ្វើសកម្មភាពគ្រប់យ៉ាងនិងដែលបានផ្លាស់ប្តូរស្ថានភាពដើមនៃបរិស្ថាន សេដ្ឋកិច្ច សង្គម វប្បធម៌ ត្រូវគោរពអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ចំពោះសកម្មភាពដែលមានស្រាប់ ដែលកំពុងដំណើរការ ឬដែលរៀបចំចាប់ផ្តើម។

**ផលប្រយោជន៍បន្ថែម:** ផលប្រយោជន៍ទាំងឡាយសម្រាប់ភូមិភាគ ឬតំបន់ដែលនៅជុំវិញគម្រោងអភិវឌ្ឍន៍ដែលបានស្នើឡើង ដែលអាចទទួលបានមកពីគម្រោង។

**បណ្តុំនៃហេតុប៉ះពាល់** : បណ្តុំនៃហេតុប៉ះពាល់ គឺ ជាហេតុប៉ះពាល់ទាំងឡាយណា ដែលកើតមក ពីហេតុប៉ះពាល់ចំនួនបន្ថែមរបស់គម្រោង ដែលបន្ថែមលើសកម្មភាពពី អតីតកាល បច្ចុប្បន្ន និង អនាគត ។

**ការឯកភាពលើគម្រោងអភិវឌ្ឍន៍** : ជាការអនុម័ត ឬ ការអនុញ្ញាត ដែលផ្តល់អោយដោយ រដ្ឋាភិបាលកម្ពុជាសម្រាប់គម្រោង ឬ ដោយស្ថាប័នផ្សេងទៀត រួមទាំង កិច្ចសន្យាសម្បទាន ។

**អ្នកទទួលហេតុប៉ះពាល់ផ្ទាល់:** ជាអ្នកទទួលហេតុប៉ះពាល់ដែលមាន សិទ្ធិតទល់ ហានិភ័យ និង ការទទួលខុសត្រូវលើបញ្ហា ។ អ្នកទាំងនោះ អាចជាអ្នកដែលនៅក្នុងតំបន់ដែលគម្រោងតាំងនៅ (ឧទាហរណ៍ សហគមន៍ដែលរងហេតុប៉ះពាល់ពីគម្រោង ) ឬ នៅក្រៅតំបន់គម្រោងតាំងនៅ (និយតករ រដ្ឋាភិបាល តំណាងស្ថាប័នហិរញ្ញវត្ថុ ឬ ដៃគូវិនិយោគទុនផ្សេងៗ។ )

**ការបាត់បង់សេដ្ឋកិច្ច (Economic Displacement):** ការបាត់បង់នូវ ទ្រព្យ ការទទួលបានទ្រព្យ ឬ ប្រភពប្រាក់ចំណូលផ្សេងៗ ឬ ការបាត់បង់នូវមធ្យោបាយក្នុងការចិញ្ចឹមជីវិត ដោយសារតែ (១) ការដកហូតយកដីធ្លី (២) ការប្រែប្រួលនៅក្នុងការប្រើប្រាស់ដីធ្លីឬការទទួលបានដីធ្លី (៣) ការដាក់កម្រិតលើការប្រើប្រាស់ដីឬលទ្ធភាពទទួលបានធនធានធម្មជាតិនានា រួមមាន ធនធានទឹក ឧទ្យានដែលត្រូវបានរៀបចំតាមផ្លូវច្បាប់ តំបន់ការពារ ឬតំបន់ដែលដាក់កម្រិតដល់ការចូលទៅដល់ ដូចជា ជលដ្ឋានអាងធម្មជាតិ និង (៤) ការប្រែប្រួលបរិស្ថាន ដែលនាំឱ្យមានកង្វល់អំពីសុខភាព ឬ ផលប៉ះពាល់ដល់ជីវភាពរស់នៅ។ ការបាត់បង់សេដ្ឋកិច្ចត្រូវរាប់បញ្ចូលទាំងអស់ ទោះបីជា ការបាត់បង់ និងការដាក់កម្រិតទាំងនោះ ជាលក្ខណៈបាត់បង់ទាំងស្រុង ឬបាត់បង់ភាគខ្លះក្តី ហើយថា មានលក្ខណៈអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក្តី។

**ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច (Ethnic Minorities Development Plan):** ផែនការអភិវឌ្ឍន៍ជនជាតិភាគតិច មានអត្ថន័យដែលត្រូវបានផ្ដល់ឱ្យវា ដោយអនុក្រិតស្ដីពី សំណង និងការផ្លាស់ទីលំនៅរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍នានា [ដែលនឹងត្រូវពង្រាងសម្រាប់ការពិចារណា] ។

**ការវាយតំលៃបរិស្ថាន:**ជាដំណើរការ ដោយយោងតាម ច្បាប់ស្ដីពីការវាយតំលៃហេតុប៉ះពាល់ បរិស្ថាន និង ច្បាប់ពាក់ព័ន្ធ ។

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ:** គឺជាការវាយតំលៃយ៉ាងលំអិត ពីហេតុប៉ះពាល់បរិស្ថាន និង សង្គម ។ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺ ជាដំណើរការសិក្សា និង ការប្រមើ មើលពីហេតុប៉ះពាល់វិជ្ជមាន និង អវិជ្ជមាន លើបរិស្ថាន និង សង្គម ដើម្បីកំនត់ពីវិធានការការពារ និង កាត់បន្ថយហេតុប៉ះពាល់លើបរិស្ថាន និង សង្គម ដែលកើតចេញពីគម្រោង និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ។

**វិញ្ញាប័នបត្រឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន:** គឺជាវិញ្ញាបនបត្រ ដែលចេញដោយ ក្រសួងបរិស្ថាន ដោយយោងតាមការវាយតំលៃបរិស្ថានរបស់គម្រោង ដែលមានចែងលំអិតអំពី ផែនការគ្រប់គ្រងបរិស្ថាន និង លក្ខខណ្ឌដែលចេញដោយក្រសួងបរិស្ថាន ។

**ផែនការគ្រប់គ្រងបរិស្ថាន:** សំដៅលើផែនការ ដែលមានចែងនៅក្នុង របាយការណ៍វាយ តំលៃហេតុប៉ះពាល់បរិស្ថាន និង សង្គម ដែលបានកំនត់ពីវិធានការការពារ និង កាត់បន្ថយ ហេតុប៉ះពាល់ ការទទួលខុសត្រូវ និង កាលវិភាគសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ផែនការតាមដាន និង ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពីគម្រោង ដោយរួមបញ្ចូលទាំង ផែនការហិរញ្ញវត្ថុសម្រាប់ សកម្មភាពបរិស្ថានក្នុងតំណាក់កាលសាងសង់ ដំណើរការ និង ការបញ្ចប់គម្រោង ។

**ប្រព័ន្ធគ្រប់គ្រងបរិស្ថាន** (**Environmental Management System**) មានអត្ថន័យដែលត្រូវបានផ្ដល់ឱ្យវា ដោយ ស្តង់ដារនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO 14001 នៃឆ្នាំ ២០០៤។

**របាយការណ៍អង្កេតតាមដានបរិស្ថាន:** ជារបាយការណ៍ស្ដីពីការតាមដាន និង វាយតំលៃបរិស្ថានរបស់គម្រោងអភិវឌ្ឍន៍ ដូចដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលដាក់ជូនក្រសួងបរិស្ថាន។ កម្មវិធីតាមដាន ត្រូវអនុវត្តតាមដំណើរការ និង ការកំនត់ពី គុណភាពបរិស្ថានដូចមានចែងក្នុង ផែនការគ្រប់គ្រងបរិស្ថាន ដែលបានអនុម័តជាផ្លូវការ ។

**គម្រោងដែលមានស្រាប់:** គម្រោងដែលមានស្រាប់ គឺ ជាគម្រោងទាំងឡាយណា ដែលកំពុងសាងសង់ ដំណើរការ ឬ នៅដំណាក់កាលបញ្ចប់នៃក្នុងវដ្តគម្រោង ដែលកំពុងអនុវត្តមុន ពេលចូលជាធរមានរបស់ច្បាប់ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

**អ្នកត្រួតពិនិត្យឯករាជ្យ:** ជាអ្នកត្រួតពិនិត្យជំនាញ ដែលមិនបានជួលមកដោយគម្រោង និង ពុំបានទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីគម្រោង ។

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង:** គឺជាការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន និង សង្គមដំបូង ដើម្បីប្រមើមើលផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គម ដែលកើតចេញពីគម្រោង និង សកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ដោយរំពឹងថានឹងមានហេតុប៉ះពាល់តិចបំផុត ដែលអាចមានវិធានការ កាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ។

**នីតិសម្បទាដី (Land Rehabilitation):** ដំណើរការនៃការធ្វើឱ្យដីត្រឡប់ទៅកាន់កម្រិតណាមួយនៃស្ថានភាពដើមរបស់វា ក្រោយពីមានការរំខាន ឬ ការធ្វើឱ្យខូចខាត ដែលទាក់ទងទៅនឹងការអនុវត្តន៍គម្រោង។

**ផែនការគ្រប់គ្រង:** ផែនការគ្រប់គ្រង គឺ ជាឧបករណ៍សម្រាប់ប្រើជាឯកសារគោលក្នុងការគ្រប់គ្រង ជាពិសេស បញ្ហាគម្រោង និង ជាយន្តការសម្រាប់ដោះស្រាយទៅនឹងសំនួរ ហេតុអ្វីជាអ្វី យ៉ាងម៉េច នរណា ប៉ុន្មាន និង ពេលណា សម្រាប់បញ្ហាទាំងនោះ ។

**បញ្ហាកេរដំណែល (Legacy Issues):** ហេតុប៉ះពាល់នៃគម្រោងមុនៗ ដែលមានឥទ្ធិពលអវិជ្ជមាន ឬដែលមិនត្រូវបានសងមកវិញនូវផលប្រយោជន៍ឬសេវាកម្មអ្វីឡើយ ឬបញ្ហាទាំងឡាយដែលមានអត្ថិភាពជាយូរអង្វែងមក ជាមួយនឹងគម្រោងបច្ចុប្បន្ន(ដែលមានស្រាប់) ឬបញ្ហាដែលមានអត្ថិភាពតាំងពីមុនមក នៅក្នុងទីតាំងបច្ចុប្បន្ននៃគម្រោងថ្មីៗ ។

**ប្រព័ន្ធគ្រប់គ្រង (Management System)**: ក្របខណ្ឌនៃដំណើរការ និងនីតិវិធីនានា ដែលត្រូវបានប្រើប្រាស់ក្នុងការធានាឱ្យបានថា អង្គការណាមួយអាចបំពេញកិច្ចការទាំងអស់ ដែលចាំបាច់តម្រូវឱ្យធ្វើ ដើម្បីសម្រេចបាននូវវត្ថុបំណងទាំងឡាយរបស់ខ្លួន។

**ការកាត់បន្ថយ (Offset):** ការអភិរក្សដែលអាចវាស់វែងបាន កើតពីសកម្មភាពដើម្បីបង្កើតអោយមាន សំណងជំងឺចិត្តលើហេតុប៉ះពាល់លើជីវចំរុះ ដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ និង យន្តការសមរម្យ សម្រាប់ជៀសវាង កាត់បន្ថយ និង ការស្តារឡើងវិញ ។ ជាទូទៅ វាមិនស្ថិតនៅក្នុងទីតាំងរបស់គម្រោងទេ ។

**ភាពប្រសើរបំផុត (Optimal)**: ដំណើរដែលស៊ីសង្វាក់គ្នាបំផុត ដោយផ្អែកលើលទ្ធផលនៃដំណើរការពិគ្រោះយោបល់ នៅពេលដែលគេរាប់បញ្ចូលនូវរាល់ការពិចារណាទាំងអស់។

**អ្នកស្នើសុំគម្រោង**: អ្នកស្នើគម្រោង គឺជាម្ចាស់គម្រោង ឬ អ្នកអភិវឌ្ឍន៍គម្រោង ដែលសំដៅលើរូបវន្ត បុគ្គលទាំងឡាយ នីតិបុគ្គល ឬ ស្ថាប័ន ដែលបានទទួលការអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវ កសាង និង អនុវត្តគម្រោង ។ អ្នកស្នើគម្រោង អាចមកពីស្ថាប័នឯកជន ស្ថាប័នរដ្ឋ ឬ ស្ថាប័នទទួលបន្ទុក អភិវឌ្ឍន៍។

**ការចូលរួមជាសាធារណៈ** : ការចូលរួមជាសាធារណៈ មានន័យថា ជាការពិគ្រោះយោបល់ និង ការចូលរួមពិភាក្សាក្នុងដំណើរការ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ការផ្លាស់ប្តូរគំនិត និង មតិយោបល់ ការទទួលយកព័តមានពីគ្រប់ភាគីដែលនឹងទទួលរងហេតុប៉ះពាល់ផ្ទាល់ និង ប្រយោល ពីគម្រោងអភិវឌ្ឍន៍ និង ដំណោះស្រាយបញ្ហា ដែលរាប់ចាប់តាំងពីកំឡុងពេលតាក់តែងផែនការ ការអនុវត្ត និង ការជួសជុលផ្នែកបរិស្ថាន និង ការស្តារឡើងវិញ មុនពេលបញ្ចប់គម្រោង ។

**ការស្តារជាថ្មី (Refurbishment)**: ស្ថានភាពនៃការស្តារទៅកាន់ស្ថានភាពល្អរបស់វាកាលពីមុន។

**គម្រោងផែនការផ្លាស់ទីលំនៅថ្មី (Resettlement Action Plan)**: ជាឯកសារ ឬ បណ្តុំឯកសារ ដែលធ្វើឡើងជាពិសេស ដើម្បីកំនត់សកម្មភាព ដែលនឹងយកមកប្រើដើម្បីជាដំណោះស្រាយបញ្ហា (ផែនការទាំងនេះ នឹង កំនត់ដោយសេចក្តីណែនាំស្តីពី សំណងជំងឺ ចិត្ត និង ដំណោះស្រាយសម្រាប់ប្រជាជនដែលរង ហេតុប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍)។ ផែនការនេះ ត្រូវបញ្ចូលអត្តសញ្ញាណរបស់អ្នកដែល ត្រូវបានទទួលការដោះស្រាយ ការសិក្សាពីសង្គម-សេដ្ឋកិច្ចសម្រាប់អ្នកដែលទទួលការដោះស្រាយ វិធានការដែលនឹងយកមកអនុវត្ត ដែលជាផ្នែកមួយនៃដំណើរការដោះស្រាយ ដោយរាប់ទាំងជំនួយ នានា ក្នុងការដោះស្រាយបញ្ហា និង ការគាំទ្រផ្នែកជីវភាព ព្រមទាំងយន្តការផ្នែកច្បាប់ និង សំណងជំងឺចិត្ត តួនាទី និង ការទទួលខុសត្រូវរបស់ស្ថាប័ន ការគ្រប់គ្រងថវិកា និង ហិរញ្ញវត្ថុ ពេលវេលា កម្មវត្ថុ និង ក្រុមគោលដៅ យន្តការកែប្រែទុក្ខព្រួយ ការតាមដានរបាយការណ៍ និង ការពិនិត្យ និង ការយល់ដឹងពីការពិគ្រោះយោបល់ ការចូលរួម និង ការផ្លាស់ប្តូរព័ត៌មាន ។

**ការជ្រើសរើសគ្រោង**: ការជ្រើសរើសគម្រោង មានន័យថា ជាការកំនត់ប្រភេទគម្រោងស្នើសុំដើម្បីពិនិត្យមើលថាតើ គម្រោងនោះចាំបាច់អោយធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ការធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**ការវាយតំលៃហេតុប៉ះពាល់សង្គម**: គឺជាដំណើរការនៃការសិក្សា និង ប្រមើមើលពី ហេតុប៉ះពាល់វិជ្ជមាន និង អវិជ្ជមាន លើផ្នែកសង្គមសេដ្ឋកិច្ចនៃសង្គមពីគម្រោង និង សកម្មភាព អភិវឌ្ឍន៍ដែលកំនត់ពីវិធានការសមរម្យដើម្បីទប់ស្កាត់ កាត់បន្ថយ និង ផ្តល់ជំងឺចិត្ត ដល់បុគ្គលដែលទទួលរងការប៉ះពាល់ពីគម្រោង ដែលអាចជាហេតុប៉ះពាល់លើជីវិត ជីវភាព សុខុមាលភាព និង សុខភាព ។

**ការវាយតំលៃបរិស្ថានជាយុទ្ធសាស្រ្ត:** ការវាយតំលៃបរិស្ថានជាយុទ្ធសាស្រ្ត សំដៅលើលំដាប់ទ្រឹស្តីនៃការវិភាគ និង ការចូលរួម ដែលមានគោលបំណង ដើម្បីរួមបញ្ចូលការពិនិត្យពិច័យផ្នែកបរិស្ថាន ទៅក្នុងគោលនយោបាយ ផែនការ និង កម្មវិធីផ្សេងៗ និង ការវាយតំលៃ ការពិនិត្យពិច័យ ទំនាក់ទំនងរវាង សេដ្ឋកិច្ច និង សង្គម ។

**ដំណើរស៊ីសង្វាក់គ្នាជាយុទ្ធសាស្រ្ត** **(Strategic Fit):**ភាពចុះសម្រុងគ្នានៃគម្រោង ជាមួយសេចក្តីត្រូវការ ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលត្រូវបានកំណត់អត្តសញ្ញាណតាមរយៈ អាទិភាព និងវត្ថុបំណងទាំងឡាយ ដែលបានដាក់ចេញនៅក្នុង ជម្រើសនៃការវាយតម្លៃ និងនៅក្នុងគោលការណ៍ និងផែនការ ដែលពាក់ព័ន្ធផ្សេងៗទៀតនៃថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាកតំបន់ និងថ្នាក់ពហុជាតិ។

**កិច្ចព្រមព្រៀងឆ្លងដែន:** ជាកិច្ចព្រមព្រៀង ដែលបង្កើតឡើងដោយរដ្ឋត្រីភាគី ស្តីពី របៀបនៃការចែករំលែកធនធាន ដែលនឹងប្រើប្រាស់ដោយភាគីដែលពាក់ព័ន្ធ ហើយនឹងដំណើរការ ដែលត្រូវធ្វើប្រតិបត្តិតាម ដើម្បីរក្សាខ្លឹមសារនៃការព្រមព្រៀងនេះ ។